ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...................សហវ.......

# សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២

## ១. សេចក្តីផ្តើម

**១.** ក្នុងឆ្នាំ ២០២០ និង ២០២១ សភាពការណ៍កម្ពុជា ក៏ដូចជាបណ្តាប្រទេសនានា ក្នុងសកលលោក ស្ថិតនៅក្រោមការគំរាមកំហែង និងយាយីពីជំងឺកូវីដ-១៩ ដែលបានបន្តរាតត្បាតទូទាំងពិភពលោក ។ ជាក់ស្តែង វិបត្តិជំងឺកូវីដ-១៩ បាននិងកំពុងបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានជាច្រើន មកលើការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ជាពិសេស នាំមកនូវការផ្លាស់ប្តូររបៀបរស់នៅ និងធ្វើការរបស់យើងផងដែរ ។ បកទល់ពេលនេះ កម្ពុជាបានបន្តគ្រប់គ្រងសភាពការណ៍បានក្នុងកម្រិតមួយល្អបង្គួរ ដោយ÷ (១). ពុំដែលឈានដល់ការបិទប្រទេស និងដាក់ប្រទេសក្នុងគ្រាមានអាសន្ន, (២). កាត់បន្ថយផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ចឱ្យស្ថិតក្នុងកម្រិតទាប និង (៣). រក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ យ៉ាងណាមិញ ការបន្តអូសបន្លាយការរាតត្បាតនៃជំងឺនេះ ពីមួយថ្ងៃទៅមួយថ្ងៃ ដែលមិនទាន់អាចកំណត់បានថានឹងបញ្ចប់នៅពេលណា នឹងបង្កើតជាហានិភ័យកាន់តែធំឡើងៗ ហើយអាចនឹងបន្តបំផ្លិចបំផ្លាញសមិទ្ធផលសង្គម-សេដ្ឋកិច្ច ដែលកម្ពុជាសម្រេចបានដោយលំបាកនាពេលកន្លងមក និងបន្ទប់បង្អាក់នូវសម្ទុះនៃការងើបឡើងវិញនូវការអភិវឌ្ឍរបស់កម្ពុជាដើម្បីឈានទៅសម្រេចនូវចក្ខុវិស័យ ២០៥០ ។

**២.** ឆ្លងកាត់បទពិសោធន៍នៃការគ្រប់គ្រងវិបត្តិជំងឺកូវីដ-១៩ ជាងមួយឆ្នាំកន្លងមកនេះ, កម្ពុជាពិតជាមិនអាចពឹងផ្អែកតែខ្លួនឯងទាំងស្រុង ហើយកាត់ផ្តាច់ចេញពីការចូលរួមចំណែកក្នុងក្របខ័ណ្ឌតំបន់និងសកល ដើម្បីទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ និងជាពិសេសជំរុញការងើបឡើងនូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចបាននោះទេ ។ ក្នុងន័យនេះ ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិត និងស្មារតីប្រុងប្រយ័ត្នខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,** កម្ពុជាបានបន្តពង្រឹងកិច្ចសហប្រតិបត្តិការកាន់តែមានភាពប្រទាក់ក្រឡា និងស្អិតរមួតជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់, ទាំងទ្វេភាគី និងពហុភាគី, និងជាពិសេសបានដាក់ចេញនូវកញ្ចប់គោលនយោបាយ និងវិធានការអន្តរាគមន៍ ក្នុងផ្នែកសេដ្ឋកិច្ច, សង្គម និងហិរញ្ញវត្ថុ ប្រកបដោយភាពបុរេសកម្ម និងប្រាកដនិយម ដើម្បីគ្រប់គ្រងស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩ និងរក្សាលំនឹងសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជនឡើងវិញ ។ ជាក់ស្តែង, រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការអន្តរាគមន៍មុតស្រួច, ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ចំនួន ៧ ជុំរួចមកហើយ ក្នុងការជួយរក្សាលំនឹងធុរកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ជាពិសេសកម្មករ-និយោជិត និងគ្រួសារក្រីក្រ និងជនងាយរងគ្រោះដែលទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ។ ជាលទ្ធផល រាជរដ្ឋាភិបាលបានផ្ដល់ការអនុគ្រោះផ្នែកពន្ធ, កាតព្វកិច្ចចំណូលមិនមែនសារពើពន្ធ និងកាតព្វកិច្ចផ្សេងៗទៀតដល់និយោជកក្នុងវិស័យទេសចរណ៍, អាកាសចរណ៍, កាត់ដេរ និងសហគ្រាសធុនតូចនិងមធ្យម និងបានឧបត្ថម្ភប្រាក់ជូនកម្មករ-និយោជិត ប្រមាណ ៤០ ម៉ឺននាក់ សម្រាប់រោងចក្រ និងសហគ្រាសដែលបានផ្អាកដំណើរការបណ្ដោះអាសន្ន, អនុវត្តកម្មវិធីសាច់ប្រាក់ពលកម្មនិងបង្កើតការងារជូនប្រជាជនប្រមាណ ១ លាននាក់ និងឧបត្ថម្ភសាច់ប្រាក់ជូនដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះប្រមាណ ២,៨ លាននាក់ ។ បន្ថែមលើនេះ, វិធានការគោលនយោបាយរូបិយវត្ថុត្រូវបានដាក់ចេញ ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃ និងបង្ការហានិភ័យហិរញ្ញវត្ថុ តាមរយៈឧបករណ៍គោលនយោបាយនានា ជាពិសេសក្នុងការបង្កើនសន្ទនីយភាពក្នុងទីផ្សារ និងការរក្សាសាធនភាពក្នុងវិស័យហិរញ្ញវត្ថុ ។

៣. ឈានចូលមកក្នុងឆ្នាំ ២០២១ ប្រទេសនានាក្នុងសកលលោកបាននិងកំពុងបន្តស្ថិតក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលនាំមកនូវផលប៉ះពាល់អវិជ្ជមាន, បញ្ហាប្រឈម និងហានិភ័យជាច្រើនដែលមិនធ្លាប់មានពីមុនមក ។ ប៉ុន្តែ ការកើនឡើងនូវការផលិត និងចែកចាយវ៉ាក់សាំងបានផ្ដល់សេចក្ដីសង្ឃឹមខ្ពស់សម្រាប់ការទប់ទល់ និងស្ដារការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឡើងវិញ ជាពិសេសក្នុងត្រីមាសទី ៣ និងទី ៤ ។ ជាមួយគ្នានេះ ការសម្របខ្លួនបានទៅនឹងបរិបទថ្មីនៃជំងឺកូវីដ-១៩ នេះ ក៏បានជួយទ្រទ្រង់ និងស្ដារសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មដែលជាមូលដ្ឋានសំខាន់នៃការងើបឡើងវិញនៃសេដ្ឋកិច្ចសកល ។ ជាក់ស្ដែង ក្នុងឆ្នាំ ២០២២ កំណើនសេដ្ឋកិច្ចសកលត្រូវបានព្យាករថាសម្រេចបាន ៤,២% ដោយផ្អែកលើសម្មតិកម្មសំខាន់នៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ គួបផ្សំនឹងគោលនយោបាយគាំទ្រនានា ដែលជំរុញសកម្មភាពផលិតកម្ម, តម្រូវការប្រើប្រាស់, បង្កើនទំនុកចិត្តសម្រាប់ការវិនិយោគ និងវំហូរមូលធនសកល ។ ទោះជាយ៉ាងនេះក្ដី និន្នាការបច្ចុប្បន្នបានបង្ហាញឱ្យឃើញថា កម្លាំង និងល្បឿននៃការងើបឡើងវិញនៃសេដ្ឋកិច្ចសកលលោក នឹងមានកម្រិតខុសគ្នា ពីប្រទេសមួយទៅប្រទេសមួយ ដោយសារគម្លាតនៃការទទួលបានវ៉ាក់សាំងរវាងប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍ, ការអនុវត្តវិធានការអន្តរាគមន៍ សុខាភិបាល, ប្រសិទ្ធភាពនៃការអនុវត្តវិធានការគាំទ្រ, សមត្ថភាពក្នុងការសម្របខ្លួនទៅនឹងវិបត្តិ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចមុនវិបត្តិ ។ មួយវិញទៀត, រលកថ្មីនៃការងើបឡើងវិញនៃជំងឺនេះ និងការបំប្លែងខ្លួនថ្មីនៃវីរុសក្សូរ៉ូណា (new variants) នៅតាមបណ្ដាប្រទេសមួយចំនួនបាននិងកំពុងបង្កើតឱ្យមានក្ដីបារម្ភថ្មី ដែលធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចសកលបន្តស្ថិតក្នុងភាពមិនប្រាកដប្រជាខ្ពស់ ក្នុងរយៈពេលមធ្យមខាងមុខ។

៤. ស្របនឹងនិន្នាការសកល, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២២ ត្រូវបានរំពឹងថានឹងបន្តឈានទៅរកគន្លងនៃកំណើនឡើងវិញ ទោះបីជានៅមានកម្រិតទាបជាងកំណើនមុនពេលមានវិបត្តិ, ដែលផ្អែកលើភាពធូរស្រាលនៃការរីករាលដាលជំងឺកូវីដ-១៩ ដោយសារការទទួលបានការចាក់វ៉ាក់សាំងយ៉ាងទូលំទូលាយពេញផ្ទៃប្រទេស ត្រឹមចុងឆ្នាំ ២០២២ និងស្របពេលកម្ពុជាបន្តសម្របខ្លួនទៅនឹងប្រក្រតីភាពថ្មី (new normal) ។ ទន្ទឹមនេះ, កម្ពុជាក៏អាចជួបប្រទះនឹងបញ្ហាប្រឈមកាន់តែស្មុគស្មាញជាងមុន ជាមួយនឹងភាពមិនប្រាកដប្រជាខ្ពស់ ដែលទាមទារឱ្យមានការពង្រឹងសមត្ថភាពផ្ទៃ-

ក្នុងឱ្យបានល្អ និងត្រូវដោះស្រាយបញ្ហាជារចនាសម្ព័ន្ធរ៉ាំរ៉ៃមួយចំនួន ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងធ្វើពិពិធកម្មសេដ្ឋកិច្ចផង និងជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកឱ្យកាន់តែមានសម្ទុះរីកចម្រើនខ្លាំងក្លាផង ។

**៥.** ក្នុងន័យនេះ ក្នុងសមរភូមិប្រយុទ្ធនឹងជំងឺកូវីដ-១៩ នេះ កម្ពុជាសម្លឹងឃើញនូវពន្លឺនៃការប្រែក្លាយវិបត្តិនេះឱ្យទៅជាកាលានុវត្តភាព តាមរយៈការបង្កើនការយកចិត្តទុកដាក់ទ្វេដង ក្នុងការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ រួមមាន÷ (១). ការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច, (២). ការជំរុញ និងលើកទឹកចិត្តការផ្លាស់ប្តូរសេដ្ឋកិច្ចក្រៅប្រព័ន្ធមកក្នុងប្រព័ន្ធ, (៣). ការកសាងប្រព័ន្ធគាំពារសង្គមរឹងមាំ និងមានភាពឆ្លើយតបខ្ពស់, (៤). ការបន្តពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ និងហិរញ្ញវត្ថុសាធារណៈ, (៥). ការបង្កើតឧបករណ៍ និងជម្រើសគោលនយោបាយបន្ថែមក្នុងការកៀរគរធនធាន, (៦). ការលើកកម្ពស់ការកសាង និងពង្រឹងការគ្រប់គ្រងប្រព័ន្ធទិន្នន័យសូចនាករសង្គម-សេដ្ឋកិច្ច, (៧). ការពង្រឹងរដ្ឋបាលសាធារណៈ, យន្តការស្ថាប័ន និងអភិបាលកិច្ច តាមរយៈការកែទម្រង់ស៊ីជម្រៅ និងការកែលម្អជាប្រព័ន្ធ និង (៨). ការចាប់យកបច្ចេកវិទ្យាឌីជីថល តាមរយៈការធ្វើបរិវត្តកម្មឌីជីថល និងឌីជីថលូបនីយកម្ម ។

**៦.** ជាមួយគ្នានេះ វិបត្តិជំងឺកូវីដ-១៩ បាននិងកំពុងធ្វើឱ្យសេដ្ឋកិច្ច និងពាណិជ្ជកម្មសកលមានការប្រែប្រួលជារចនាសម្ព័ន្ធ ដែលកម្ពុជាត្រូវយកមកគិតគូរក្នុងការសម្របខ្លួន មានជាអាទិ៍÷

**(១)- និម្មាបនកម្មសេដ្ឋកិច្ចសកល (global economic architecture) បង្ហាញនូវនិន្នាការថ្មីមួយកាន់តែច្បាស់÷** ការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម (reshoring and relocation) ដើម្បីធានានិរន្តរភាពនៃខ្សែច្រវាក់ផលិតកម្ម នឹងនាំមកនូវការវិនិយោគក្នុងតំបន់ដែលមានសក្តានុពលថ្មី ខណៈឥទ្ធិពលនៃសង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យារវាងប្រទេសមហាអំណាច នឹងអាចធ្វើឱ្យច្រវាក់ផ្គត់ផ្គង់ និងនិយាមបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ ក្នុងតំបន់ និងសកល បែងចែកចេញជាប៉ូលផ្សេងៗគ្នា ។ ជាមួយគ្នានេះ, សណ្ឋាននៃការវិនិយោគ និងពាណិជ្ជកម្មសកល នឹងមានការផ្លាស់ប្តូរ ទាំងទិសដៅ, មធ្យោបាយ និងប្រភេទទំនិញ និងសេវាកម្ម ។

**(២)- កំណើនសេដ្ឋកិច្ចរយៈពេលខ្លីនឹងងើបឡើងក្នុងកម្រិតទាបជាងនិន្នាការមុនវិបត្តិ÷** ការកើនឡើងនៃគោលនយោបាយគាំពារនិយម និងគោលនយោបាយដែលផ្តោតសំខាន់តែលើការជំរុញសេដ្ឋកិច្ចក្នុងស្រុក (inward looking) នឹងបង្អាក់និន្នាការសាកលភាវូបនីយកម្ម និងធ្វើឱ្យកំណើនសេដ្ឋកិច្ច និងពាណិជ្ជកម្មសកល ស្ថិតក្រោមបន្ទាត់សក្តានុពល (growth potential) ។ លំហូរពាណិជ្ជកម្មសកល និងលំហូរមនុស្ស នឹងងើបឡើងមកវិញក្នុងល្បឿនយឺត អាស្រ័យខ្លាំងលើការគ្រប់គ្រងការឆ្លងជំងឺកូវីដ-១៩ ខណៈលំហូរមូលធនសកល និងការវិនិយោគរវាងប្រទេសនិងប្រទេស និងរវាងតំបន់និងតំបន់ នឹងប្រព្រឹត្តទៅក្នុង ភាពរឹតត្បិត និងប្រុងប្រយ័ត្នខ្ពស់ជាងមុន ។

**(៣)- ការសម្របខ្លួនទៅនឹងនិន្នាការថ្មីៗកាន់តែទទួលបានការយកចិត្តទុកដាក់ខ្ពស់÷** ការបង្កើនល្បឿនឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថល គួបផ្សំការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ និងស្វ័យប្រវត្តិកម្ម នឹងបង្ហាញនូវតួនាទីកាន់តែសំខាន់នៃបច្ចេកវិទ្យាឌីជីថលក្នុងសកម្មភាពសេដ្ឋកិច្ច, ធុរកិច្ច និងអភិបាលកិច្ច ។ ជាមួយគ្នានេះ, ការបង្កើនការយកចិត្តទុកដាក់ជាងមុនលើបញ្ហាការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ នឹងនាំមកនូវការវិនិយោគច្រើនជាងមុនលើប្រភពថាមពលកកើតឡើងវិញ និងបច្ចេកវិទ្យាបៃតង ។

៧. ក្នុងបរិបទដែលកម្ពុជាត្រូវបោះជំហានលើគន្លងអភិវឌ្ឍន៍ថ្មី ផ្សារភ្ជាប់នឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មសកល និងស្របពេលដែលវិបត្តិជំងឺកូវីដ-១៩ បានបង្ហាញឱ្យឃើញកាន់តែច្បាស់នូវសារៈសំខាន់នៃតួនាទីមិនអាចខ្វះបានរបស់ស្ថាប័នរដ្ឋ, ដែលតម្រូវឱ្យកម្ពុជាបន្ថែមល្បឿន និងភាពស៊ីជម្រៅនៃការកសាងនូវប្រព័ន្ធរដ្ឋបាលសាធារណៈមួយដែលកាន់តែស្អាតស្អំ, ឆ្លាតវៃ និងមានសមត្ថភាពខ្លាំងពូកែ ដើម្បីអាចគ្រប់គ្រង និងដោះស្រាយបញ្ហាសង្គម និងសេដ្ឋកិច្ច ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងរយៈពេលវែង ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងផ្តោតលើទិសដៅគោលនយោបាយអាទិភាព ស្របនឹង គោលដៅជាយុទ្ធសាស្ត្រទាំង ៤ ដូចមានចែងក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** ដើម្បី **កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា ទាំងក្នុងបរិការណ៍វិបត្តិជំងឺកូវីដ-១៩ និងក្រោយពេលវិបត្តិ ។

៨. ជារួម ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានរៀបចំក្នុងគោលបំណង ធ្វើឱ្យកម្ពុជាងើបឡើងវិញខ្លាំង និងរឹងមាំជាងមុនពេលមានវិបត្តិ ដោយម្យ៉ាង គាំទ្រការបន្តគ្រប់គ្រងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ជាមួយនឹងអភិក្រមរៀនរស់ជាមួយជំងឺកូវីដ-១៩ និងម្យ៉ាងទៀត សម្របខ្លួននឹងប្រក្រតីភាពថ្មី ជាពិសេសការបន្តកែទម្រង់ជារចនាសម្ព័ន្ធ ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវភាពធន់នឹងវិបត្តិក្នុងគោលដៅរក្សាចីរភាពនៃកំណើន និងការអភិវឌ្ឍរយៈពេលវែង ។

## ២. សមិទ្ធផលសេដ្ឋកិច្ចឆ្នាំ ២០២០

៩. ក្នុងឆ្នាំ ២០២០ ពិភពលោកទាំងមូលបានជួបប្រទះនឹងវិបត្តិសុខភាពសាធារណៈជាសកល ដែលបណ្តាលមកពីការរីករាលដាលយ៉ាងឆាប់រហ័សនៃជំងឺកូវីដ-១៩ រហូតឈានទៅដល់ការបិទប្រទេស, ការបិទទីក្រុង, ការរឹតត្បិតការធ្វើដំណើរ និងការដាក់ចេញនូវវិធានការម៉ឺងម៉ាត់មួយចំនួនទៀត សំដៅទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ជាលទ្ធផល វិធានការទាំងនោះបានបន្ថែមសម្ពាធ និងបង្អាក់សកម្មភាពផលិតកម្ម, ការផ្គត់ផ្គង់, ការប្រើប្រាស់ និងការវិនិយោគ ដែលបានរុញច្រានកំណើនសេដ្ឋកិច្ចសកលក្នុងឆ្នាំ ២០២០ ឱ្យធ្លាក់ចុះគួរឱ្យកត់សម្គាល់ ក្នុងអត្រា -៣,៥% ។ ដោយសារជាប្រទេសមានសេដ្ឋកិច្ចបើកចំហខ្ពស់, សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០២០ សម្រេចបានកំណើនអវិជ្ជមានក្នុងអត្រា -៣,១% ដោយសារការធ្លាក់ចុះនៃវិស័យសេវាកម្ម និងវិស័យឧស្សាហកម្ម ខណៈវិស័យកសិកម្មនៅរក្សាបានកំណើនវិជ្ជមាន ។ ការវាយតម្លៃជារួមបង្ហាញថា វិស័យសេវាកម្មមានកំណើនអវិជ្ជមាន ក្នុងអត្រា -៦,៧% ដោយសារការធ្លាក់ចុះយ៉ាងគំហុកនៃអនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន និងកំណើនអវិជ្ជមាននៃអនុវិស័យអចលនទ្រព្យ និងអនុវិស័យផ្សេងទៀតដែលគាំទ្រដល់វិស័យទេសចរណ៍ ។ ជាមួយគ្នានេះ វិស័យឧស្សាហកម្មត្រូវបានវាយតម្លៃថាមានកំណើនអវិជ្ជមាន ក្នុងអត្រា -១,២% ដែលបណ្តាលមកពីការធ្លាក់ចុះនៃអនុវិស័យកាត់ដេរ និងអនុវិស័យសំណង់ ខណៈអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរនៅរក្សាបានកំណើនខ្ពស់ ។ ទោះជាយ៉ាងនេះក្តី, វិស័យកសិកម្មត្រូវបាន

វាយតម្លៃថាមានកំណើនវិជ្ជមានក្នុងអត្រា ០,៥% ដែលគាំទ្រដោយកំណើនទាបនៃអនុវិស័យដំណាំ និងការងើបឡើងវិញនៃអនុវិស័យចិញ្ចឹមសត្វ និងអនុវិស័យនេសាទ បន្ទាប់ពីកំណើនអវិជ្ជមានក្នុងឆ្នាំ ២០១៩ ។

**១០.** ជាមួយគ្នានេះ, ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ច ក៏បានជះឥទ្ធិពលអវិជ្ជមានដល់ស្ថានភាពហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាក្នុងឆ្នាំ ២០២០ ផងដែរ ។ ជាក់ស្តែង ការប្រមូលចំណូលក្នុងស្រុក (តួលេខបណ្តោះអាសន្ន) សម្រេចបានប្រមាណ ២១,៥១% នៃ ផសស ដែលធ្លាក់ចុះ ក្នុងអត្រា -១៥,៦% ធៀបនឹងឆ្នាំ ២០១៩ ដោយសារការថមថយនៃសកម្មភាពអាជីវកម្មនានា ដែលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ព្រមទាំងការដាក់ចេញនូវគោលនយោបាយអនុគ្រោះ ឬបន្ធូរបន្ថយពន្ធ ។ ជាការឆ្លើយតប រាជរដ្ឋាភិបាលបានធ្វើវិចារណកម្មនូវមុខសញ្ញាចំណាយដែលពុំសូវចាំបាច់ និងលែងចាំបាច់មួយចំនួន ដើម្បីបង្វែរទិសនៃការប្រើប្រាស់ថវិកា ទៅដោះស្រាយតម្រូវការបន្ទាន់ និងចាំបាច់ភ្លាមៗ ដែលផ្តោតលើអាទិភាពចំនួន ៤ រួមមាន÷(១). ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, (២). ការរក្សាលំនឹងជីវភាពប្រជាជន ជាពិសេសសម្រាប់ប្រជាជនក្រីក្រ និងអ្នកបាត់បង់ការងារ, (៣). ការរក្សាលំនឹងធុរកិច្ច និងអាជីវកម្ម ជាពិសេសជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និង (៤).ការរក្សាឱ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម ។ ជាលទ្ធផល ការអនុវត្តចំណាយក្នុងឆ្នាំ ២០២០ (តួលេខបណ្តោះអាសន្ន) ស្ថិតក្នុងរង្វង់ ២៩,៦០% នៃ ផសស សមមូលនឹងកំណើន ១២,៦% ធៀបនឹងការអនុវត្តក្នុងឆ្នាំ ២០១៩ ។ ជារួម ឱនភាពថវិកាក្នុងឆ្នាំ ២០២០ បានរីកដល់ ៩,២៥% នៃ ផសស ដែលធំជាងច្បាប់ថវិកាប្រមាណជិត ៣ ពិន្ទុភាគរយ ប៉ុន្តែស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ។

## ៣. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

**១១.** ក្នុងឆ្នាំ ២០២១ និង ២០២២ សេដ្ឋកិច្ចសកលត្រូវបានព្យាករថានឹងងើបឡើងវិញ ក្នុងអត្រាកំណើន ៥,៥% និង ៤,២% រៀងគ្នា ក្រោមការរំពឹងទុកថាវ៉ាក់សាំងការពារជំងឺកូវីដ-១៩ នឹងត្រូវបានចែកចាយក្នុងឆ្នាំ ២០២១ នៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចអភិវឌ្ឍ និងប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់មួយចំនួន ព្រមទាំងពង្រីកវិសាលភាពទៅស្ទើរគ្រប់ប្រទេសនៅលើសកលលោកក្នុងឆ្នាំ ២០២២ ។ ការងើបឡើងវិញនេះ ក៏រួមចំណែកពីអន្តរាគមន៍របស់រដ្ឋាភិបាល និងធនាគារកណ្តាលនៃបណ្តាប្រទេសនៅលើសកលលោក តាមរយៈការអនុវត្តគោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុ ។ ក្នុងនោះ កំណើនសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូពាណិជ្ជកម្ម និងវិនិយោគសំខាន់ៗរបស់កម្ពុជា ត្រូវបានរំពឹងថានឹងងើបឡើងវិញ រួមមាន សហរដ្ឋអាមេរិក ក្នុងអត្រា ៥,១% និង ២,៥% និងតំបន់ចាយប្រាក់អឺរ៉ូ ក្នុងអត្រា ៤,២% និង ៣,៦% ក្នុងឆ្នាំ ២០២១ និង ២០២២ រៀងគ្នា ។ ដោយឡែក សេដ្ឋកិច្ចចិន ត្រូវបានរំពឹងថានឹងបន្តកំណើនខ្ពស់ ក្នុងអត្រា ៨,១% ក្នុងឆ្នាំ ២០២១ និង ៥,៦% ក្នុងឆ្នាំ ២០២២ ។ ការព្យាករនៃកំណើនសេដ្ឋកិច្ចសកលក្នុងឆ្នាំ ២០២១ និង ២០២២ នេះ ត្រូវបានគិតបញ្ចូលនូវកត្តាមួយចំនួនដែលនឹងអាចកើតមានឡើង ដូចជា ការធ្លាក់ចុះនូវផលិតភាព, ការក្ស័យធនរបស់ក្រុមហ៊ុនធំៗ, និងការបង្វែរធនធានពីវិស័យមួយទៅវិស័យមួយទៀត ឬពីតំបន់មួយទៅតំបន់មួយទៀត ជាដើម ។ លើសពីនេះ ការព្យាករកំណើនសេដ្ឋកិច្ចខាងលើនៅតែស្ថិតក្នុងភាពមិនប្រាកដប្រជាខ្ពស់ ដោយសារការបំប្លែងខ្លួនថ្មីនៃវីរុសកូរ៉ូណា (new variants) ដែលនឹងអាចបន្តរីករាលដាល និងប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ចជាបន្តបន្ទាប់ ។

១២. សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០២១ ត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រាកំណើនទាប ប្រមាណ ៤,០% ពី -៣,១% ក្នុងឆ្នាំ ២០២០ ក្រោមបរិបទនៃការអូសបន្លាយនៃជំងឺកូវីដ-១៩ និងការរំពឹងទុកនូវការងើបឡើងវិញក្នុងកម្រិតយឺតនៃតម្រូវការសកល, ការបន្ធូរបន្ថយនូវការរឹតបន្តឹងលើការធ្វើដំណើរ និងការសម្របខ្លួនទៅនឹងប្រក្រតីភាពថ្មី ព្រមទាំងបានរាប់បញ្ចូលនូវវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាលដែលក៏ជាផ្នែកសំខាន់ក្នុងការជំរុញកំណើន ។ ឈរលើមូលដ្ឋាននេះ វិស័យឧស្សាហកម្មត្រូវបានព្យាករថានឹងមានកំណើនវិជ្ជមានក្នុងកម្រិតទាប ដោយសារការរំពឹងទុកការងើបឡើងវិញយឺតនៃអនុវិស័យសំណង់ និងអនុវិស័យកាត់ដេរ ខណៈអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរនឹងរក្សាបានកំណើនល្អប្រសើរ ។ ទន្ទឹមនេះ, វិស័យសេវាកម្ម ត្រូវបានរំពឹងថានឹងមានសម្ទុះកំណើនឡើងវិញ ប៉ុន្តែក្នុងអត្រាយឺតជាងនិន្នាការធម្មតា ដោយសារកំណើនទាបនៃអនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន, អនុវិស័យអចលនទ្រព្យ និងអនុវិស័យគាំទ្រផ្សេងទៀត ។ រីឯ វិស័យកសិកម្មត្រូវបានព្យាករថានឹងបន្តកំណើនប្រហាក់ប្រហែលគ្នាទៅនឹងនិន្នាការធម្មតា ក្រោមការរំពឹងទុកនូវកំណើនល្អឡើងវិញនៃអនុវិស័យដំណាំ និងអនុវិស័យនេសាទ ខណៈអនុវិស័យចិញ្ចឹមសត្វមានកំណើនថមថយ ។ ដោយឡែក ក្នុងឆ្នាំ ២០២២, សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងសម្រេចបានកំណើនក្នុងរង្វង់ ៥,៧% ដោយសារការបន្តងើបឡើងវិញ នៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងសកល ទាំងសកម្មភាពផលិតកម្ម, តម្រូវការ, ការវិនិយោគ និងវំហូរមនុស្ស ដែលនឹងជំរុញដល់ការងើបឡើងវិញនូវអនុវិស័យជំរុញកំណើនសំខាន់ៗ ដូចជាអនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន, អនុវិស័យកាត់ដេរ, អនុវិស័យសំណង់ និងអចលនទ្រព្យ និងអនុវិស័យគាំទ្រផ្សេងទៀត ។ ផ្អែកលើសម្មតិកម្មខាងលើ, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២១ និង ២០២២ ត្រូវបានព្យាករដូចខាងក្រោម÷

១៣. *វិស័យកសិកម្ម* ត្រូវបានព្យាករថានឹងមានកំណើន ក្នុងរង្វង់ ១,៣% ក្នុងឆ្នាំ ២០២១ និង ១,១% ក្នុងឆ្នាំ ២០២២ ដោយសារកំណើនល្អប្រសើរឡើងវិញនៃអនុវិស័យដំណាំ និងការបន្តកំណើនវិជ្ជមាននៃអនុវិស័យនេសាទ ខណៈអនុវិស័យចិញ្ចឹមសត្វត្រូវបានរំពឹងថាមានកំណើនថមថយត្រឡប់ទៅរកនិន្នាការធម្មតាវិញ បន្ទាប់ពីមានកំណើនខ្ពស់ក្នុងឆ្នាំ ២០២០ ។

១៤. អនុវិស័យដំណាំ ត្រូវបានព្យាករថាសម្រេចបានកំណើន ១,៦% ក្នុងឆ្នាំ ២០២១ និង ១,២% ក្នុងឆ្នាំ ២០២២ ដោយសារការកើនឡើងនៃផលិតកម្មដំណាំស្រូវ, កៅស៊ូ, ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម ។ ផលិតកម្មដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម ដូចជា ដំឡូងមី, ស្វាយចន្ទី, ស្វាយ, ចេកអំបូងលឿង, ពោត, មៀនប៉ៃលិន (តាង៉ែន) និងបន្លែ ជាដើម ត្រូវបានព្យាករថានឹងមានកំណើនល្អប្រសើរ ដោយសារការរំពឹងទុក ការកើនឡើងវិនិយោគទាំងក្នុងស្រុក និងពីបរទេសលើការកែច្នៃផលិតផលកសិកម្ម ដែលជាលទ្ធផលនៃការអនុវត្តវិធានការគោលនយោបាយ រួមបញ្ចូល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣, ការបង្កើនវិនិយោគសាធារណៈ និងអន្តរាគមន៍របស់រាជរដ្ឋាភិបាល ជាពិសេស ការផ្តល់ហិរញ្ញប្បទានក្នុងការជំរុញផលិតកម្មក្នុងស្រុក និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រួមមាន "កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន", "កិច្ចព្រមព្រៀងពាណិជ្ជ-

កម្មសេរីកម្ពុជា-កូរ៉េ" និង "កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)" ជាដើម ដែលនឹងបន្តជំរុញដល់ការនាំចេញ ។

**១៥.** អនុវិស័យនេសាទ ត្រូវបានព្យាករថានឹងកើនឡើងមកក្នុងអត្រា ១,៥% ក្នុងឆ្នាំ ២០២១ និង ១,៤% ក្នុងឆ្នាំ ២០២២ ក្រោមការរំពឹងទុកនូវការកើនឡើងការវិនិយោគលើអនុវិស័យវារីវប្បកម្ម ដោយសារការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ តាមរយៈការគាំទ្រផ្នែកហិរញ្ញប្បទានសម្បទាន, ការផ្សព្វផ្សាយបច្ចេកទេស និងការប្រើប្រាស់ពូជត្រីប្រកបដោយប្រសិទ្ធភាពខ្ពស់ និងគុណភាព ខណៈផលនេសាទទឹកសាបបន្តមានកំណើនទាបធៀបនឹងនិន្នាការធម្មតា ក្រោមការរំពឹងទុកកម្រិតទឹកទន្លេទាប ដែលមិនអំណោយផលដល់ការបង្កកំណើតត្រី ។

**១៦.** អនុវិស័យចិញ្ចឹមសត្វ ត្រូវបានព្យាករថានឹងមានកំណើនថមថយមកនិន្នាការធម្មតាវិញ ក្នុងរង្វង់ ០,៦% ក្នុងឆ្នាំ ២០២១ និង ០,៨% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកនូវកំណើនថមថយមកវិញនៃផលិតកម្មជ្រូក បន្ទាប់ពីមានសម្ទុះខ្លាំងក្នុងឆ្នាំ ២០២០ ខណៈផលិតកម្មបក្សីនៅបន្តកំណើនល្អ ។ ក្នុងនោះ ផលិតកម្មជ្រូកបែបពាណិជ្ជកម្មអាចនឹងមានកំណើនថមថយបន្តិច ដែលបណ្តាលមកពីការកើនឡើងនូវការនាំចូលជ្រូក បន្ទាប់ពីស្ថានភាពជំងឺប៉េស្តជ្រូកអាហ្វ្រិក នៅប្រទេសជិតខាងមានភាពធូរស្រាល ។ យ៉ាងណាមិញ, ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារនឹងមានកំណើនល្អឡើងវិញជាបណ្តើរៗ ដោយសារភាពធូរស្រាលនៃជំងឺប៉េស្តជ្រូកអាហ្វ្រិក គួបផ្សំនឹងអន្តរាគមន៍របស់រាជរដ្ឋាភិបាល និងការអនុវត្តគម្រោងរបស់ដៃគូអភិវឌ្ឍន៍នានា ។ ទន្ទឹមនេះ ផលិតកម្មបក្សីនឹងបន្តមានកំណើនល្អ ដោយសារតែការ-រំពឹងទុកនូវការកើនឡើងតម្រូវការក្នុងស្រុក ។

**១៧.** ទោះជាយ៉ាងនេះក្តី, វិស័យកសិកម្មនៅបន្តជួបប្រទះបញ្ហាប្រឈមជារចនាសម្ព័ន្ធ រួមមាន កំណើនទាបនៃផលិតភាពដីនិងផលិតភាពពលកម្ម, ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, ភាពទន់ខ្សោយនៃការធ្វើពាណិជ្ជ-បនីយកម្ម និងពិពិធកម្មកសិកម្ម និងកង្វះការកែច្នៃផលិតផលកសិកម្មឱ្យអស់ពីសក្តានុពលដើម្បីទាញយកតម្លៃបន្ថែម ។ ក្នុងន័យនេះ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនេះ និងជំរុញវិស័យកសិកម្មឱ្យមានកំណើនខ្ពស់ឡើងវិញសំដៅគាំទ្រកំណើនសេដ្ឋកិច្ច និងលើកកម្ពស់សន្តិសុខស្បៀង ក្នុងរយៈពេលមធ្យម និងវែង, រាជរដ្ឋាភិបាលនឹងបន្តអនុវត្តវិធានការគោលនយោបាយលើ÷ (១). ការវិនិយោគលើផលិតកម្មពូជសុទ្ធដែលមានគុណភាពល្អ, (២). ការវិនិយោគលើប្រព័ន្ធស្រោចស្រពខ្នាតតូច និងមធ្យម ក្នុងតំបន់ដែលមានសក្តានុពលស្រូវក្រអូប និងដំណាំឧស្សាហកម្មផ្សេងទៀត, (៣). ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ជាពិសេសផ្សារបោះដុំកសិផល, មន្ទីរពិសោធន៍, បន្ទប់ត្រជាក់សម្រាប់ស្តុកទុកកសិផល ជាដើម, (៤). ការស្រាវជ្រាវ និងអភិវឌ្ឍន៍, (៥). ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលស្របនឹងតម្រូវការទីផ្សារ, (៦). ការជំរុញការបង្កើតឧទ្យានកសិ-ឧស្សាហកម្ម (agro-industrial park), (៧). ការ-អភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគុណភាព (quality infrastructure system) ដើម្បីឆ្លើយតបទៅនឹងតម្រូវការស្តង់-ដារសម្រាប់ការនាំចេញ, (៨). ការសម្របសម្រួលស្ថាប័ន និង (៩). ការជំរុញការអនុវត្តកិច្ចសន្យាកសិកម្ម (contract farming) ឱ្យកាន់តែទូលំទូលាយ ។

១៨. *វិស័យឧស្សាហកម្ម* ត្រូវបានព្យាករថានឹងមានកំណើន ក្នុងអត្រា ៥,៩% ក្នុងឆ្នាំ ២០២១ និង ៨,២% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកនូវការងើបឡើងវិញជាបណ្តើរៗនៃសកម្មភាពផលិតកម្ម, តម្រូវការសកល និង លំហូរទុនវិនិយោគ ។

១៩. អនុវិស័យកាត់ដេរ ត្រូវបានព្យាករថានឹងកើនឡើងវិញក្នុងអត្រាកំណើនទាប ៤,៦% ក្នុងឆ្នាំ ២០២១ និង ៦,០% ក្នុងឆ្នាំ ២០២២ ដោយសារការងើបឡើងវិញនូវតម្រូវការសកល បន្ទាប់ពីការយាយីដ៏ធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីដ-១៩ ជាពិសេសមកលើប្រទេសដៃគូនាំចេញសំខាន់ៗ របស់កម្ពុជា រួមមាន សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ។ ទោះជាយ៉ាងនេះក្តី អនុវិស័យកាត់ដេរ ក៏អាចជួបប្រទះនឹងហានិភ័យ និងបញ្ហាប្រឈមមួយចំនួនរួមមាន ភាពមិន-ច្បាស់លាស់នៃប្រព័ន្ធអនុគ្រោះពន្ធពីទីផ្សារខាងក្រៅ ពិសេសពាក់ព័ន្ធនឹងប្រព័ន្ធ EBA ក៏ដូចជា ប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) របស់សហរដ្ឋអាមេរិកលើផលិតផលធ្វើដំណើរ, ភាពមានកម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងផលិតកម្ម និងការបន្តកើនឡើងការប្រកួតប្រជែងពីខាងក្រៅ ។ ជាការឆ្លើយតប, រាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្ត "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២១-២០២៥" ដើម្បីទាក់ទាញការ-វិនិយោគមានតម្លៃបន្ថែមខ្ពស់ ដោយផ្តោតការយកចិត្តទុកដាក់លើ÷ (១). ការ-បន្តពង្រឹងធនធានមនុស្សដើម្បីបង្កើនផលិតភាព និងបង្កើតគន្លងអាជីពសម្រាប់កម្មករ-និយោជិត, (២). ការបន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងសុខុមាលភាពរបស់កម្មករ-និយោជិត, (៣). ការលើកកម្ពស់ការវិនិយោគក្នុងស្រុក និងបរទេស ដើម្បីបង្កើនតម្លៃបន្ថែមក្នុងអនុវិស័យនេះ, (៤). ការទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំ-ទ្រសម្រាប់បម្រើឱ្យអនុវិស័យនេះ និង (៥). ការជំរុញការធ្វើពិពិធកម្មទីផ្សារសម្រាប់ការនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងកាបូប ។

២០. អនុវិស័យសំណង់ ត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រាកំណើនទាប ក្នុងរង្វង់ ២,៩% ក្នុងឆ្នាំ ២០២១ និង ៧,៨% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកនូវការត្រឡប់មកវិញ នៃលំហូរទុនវិនិយោគពីបរទេស និងការងើបឡើងវិញនូវតម្រូវការក្នុងស្រុក ។ ការបន្តរីកធំនៃឥណទានផ្តល់ទៅអនុវិស័យសំណង់ អាចនឹងជួយប៉ះប៉ូវបានមួយផ្នែកតូចពីការរំពឹងទុកនូវការរឹតត្បិតលំហូរទុនវិនិយោគពីប្រទេសចិន តាមរយៈការកើនឡើងនូវហិរញ្ញប្បទានក្នុងស្រុក (domestic financing), ប៉ុន្តែការបន្តកំណើនខ្ពស់នៃឥណទានក្នុងស្រុកនេះ អាចបង្កជាហានិភ័យដល់អនុវិស័យសំណង់ និងវិស័យហិរញ្ញវត្ថុទាំងមូលផងដែរ (macro-financial linkage) ស្របពេលដែលកំណើនសេដ្ឋកិច្ចជារួមបានរំពឹងថានឹងងើបឡើងវិញក្នុងកម្រិតទាប ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងបន្តតាមដានដោយយកចិត្តទុកដាក់លើការវិវត្តនៃអនុវិស័យនេះ ដើម្បីដាក់ចេញគោលនយោបាយអន្តរាគមន៍បានទាន់ពេលវេលា សំដៅបញ្ចៀសហានិភ័យដែលអាចកើតឡើង ។ ជារួម អត្រាកំណើននេះស្ថិតក្នុងនិន្នាការទាបជាងធម្មតានៅឡើយ ដោយហេតុថាអនុវិស័យនេះត្រូវការពេលវេលាដើម្បីស្តារទំនុកចិត្តក្នុងការវិនិយោគ ។

២១. អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ដែលកំពុងបង្ហាញនូវសញ្ញានៃការធ្វើពិពិធកម្មទំនិញនាំចេញ ត្រូវបានព្យាករថានឹងបន្តមានកំណើនខ្ពស់ក្នុងអត្រា ១២,៥% ក្នុងឆ្នាំ ២០២១ និង ១២,៧% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកនូវការបន្តកើនឡើងសកម្មភាពផលិតកម្ម ដើម្បីបម្រើការប្រើប្រាស់ក្នុងស្រុក និងការនាំចេញ

ផលិតផលកម្មន្តសាលមិនមែនកាត់ដេរ រួមមាន កង់, ក្តារបន្ទះ, គ្រឿងសង្ហារិម, បន្ទះសូឡា, គ្រឿងបង្គុំអេឡិចត្រូនិក និង ផលិតផលកសិ-ឧស្សាហកម្ម ដូចជា អង្ករ និងកៅស៊ូ ជាដើម ។ ជាមួយគ្នានេះ, ការរំពឹងទុកនូវការបន្តនិន្នាការនៃការផ្លាស់ប្តូរទីតាំងរោងចក្រ (factory relocation) និងការធ្វើពិពិធកម្មប្រភពផលិតកម្ម (production base diversification) របស់ក្រុមហ៊ុនអន្តរជាតិមួយចំនួនមកកម្ពុជា ដែលបណ្តាលមកពីឥទ្ធិពលនៃសង្គ្រាមពាណិជ្ជកម្ម និងការបង្វែរពីច្រវាក់ផលិតកម្មសកលមកជាច្រវាក់ផលិតកម្មតំបន់ ក៏នឹងជួយជំរុញដល់កំណើននៃអនុវិស័យនេះផងដែរ ។ ទន្ទឹមនេះ អនុវិស័យនេះក៏ត្រូវបានគាំទ្រដោយការដាក់ចេញជាបន្តបន្ទាប់នូវគោលនយោបាយគាំទ្រវិស័យឯកជន ជាពិសេសការលើកកម្ពស់សហគ្រិនភាព, ការអភិវឌ្ឍជំនាញសម្រាប់កម្មករ-និយោជិត និងកម្មវិធីគាំទ្រសហគ្រាសធុនតូច និងមធ្យម ជាដើម ។ បន្ថែមលើនេះ ការដាក់ចេញ "ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា" ក៏នឹងចូលរួមចំណែកបង្កើនបរិយាកាសវិនិយោគឱ្យកាន់តែមានភាពទាក់ទាញ និងប្រសើរជាងមុន ។ លើសពីនេះទៀត ការពង្រីកទីផ្សារនាំចេញតាមរយៈការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដូចជា "កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន", "កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ" និង "កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)" ក៏ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមួយចំនួនទៀត ត្រូវបានរំពឹងថានឹងចូលរួមចំណែកលើកស្ទួយ និងជំរុញកំណើននៃអនុវិស័យនេះតាមរយៈការជំរុញ និងធ្វើពិពិធកម្មទីផ្សារនាំចេញ ។ ទោះជាយ៉ាងនេះក្តី, អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ នៅតែមានការប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធមួយចំនួន ដូចជា កង្វះវត្ថុធាតុដើមក្នុងស្រុក, ថ្លៃអគ្គិសនីខ្ពស់ និងកង្វះខាតប្រភេទអាជីវកម្មធុនកណ្តាល (missing middles) ។ ដើម្បីឱ្យអនុវិស័យនេះអាចរួមចំណែកឱ្យអស់សក្តានុពលនៅក្នុងសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការអនុវត្ត "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥", បន្តជំរុញយន្តការ "គណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម" ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាជារចនាសម្ព័ន្ធដែលមានលក្ខណៈអន្តរស្ថាប័ន និងរៀបចំ "ផែនការមេដើម្បីអភិវឌ្ឍនិងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង" សំដៅផ្សារភ្ជាប់ខ្សែច្រវាក់តម្លៃតំបន់ និងសកល ។

**២២.** ***វិស័យសេវាកម្ម*** ត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រាកំណើន ៣,៤% ក្នុងឆ្នាំ ២០២១ និង ៥,១% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកភាពប្រសើរឡើងវិញយឺតនៃសកម្មភាពធ្វើដំណើរ និងលំហូរទុនវិនិយោគពីបរទេស ដែលនឹងជួយជំរុញដល់អនុវិស័យអចលនទ្រព្យ, សណ្ឋាគារនិងភោជនីយដ្ឋាន និងអនុវិស័យដែលគាំទ្រដល់សកម្មភាពទេសចរណ៍ ។

**២៣.** អនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន ត្រូវបានព្យាករថានឹងងើបឡើងវិញបន្តិចពីមូលដ្ឋានទាបក្នុងឆ្នាំ ២០២០ មកក្នុងអត្រា ០,៣% ក្នុងឆ្នាំ ២០២១ និង ៤,៨% ក្នុងឆ្នាំ ២០២២ ។ ក្នុងឆ្នាំ ២០២១ អនុវិស័យនេះត្រូវបានប៉ាន់ស្មានថាកើនឡើងវិញបន្តិច ដោយសារការរំពឹងទុកការកើនឡើងភ្ញៀវទេសចរក្នុងស្រុក ដែលអាចប៉ះប៉ូវមួយផ្នែកដល់ការបន្តធ្លាក់ចុះនៃភ្ញៀវទេសចរអន្តរជាតិ ដែលបណ្តាលមកពីការបន្តអូសបន្លាយនៃការរីករាលដាលជំងឺកូវីដ-១៩ ។ ក្នុងឆ្នាំ ២០២២, អនុវិស័យនេះ ត្រូវបានរំពឹងថានឹងបន្តកំណើនទាប ដោយសារការកើនឡើងក្នុងកម្រិតទាបនៃចំនួនភ្ញៀវ

ទេសចរអន្តរជាតិ បន្ទាប់ពីជំងឺកូវីដ-១៩ បានស្រាកស្រាន្ត ។ ទន្ទឹមនេះ បន្ថែមលើផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដែលបណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩ អនុវិស័យនេះក៏ប្រឈមនឹងបញ្ហាមួយចំនួន រួមមាន ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, សមត្ថភាពស្ថាប័ន និងការធ្វើពិពិធកម្មគោលដៅ, ផលិតផល និងសេវាទេសចរណ៍ ព្រមទាំងការបាត់បង់ តម្លៃបន្ថែមសេដ្ឋកិច្ចដោយសារ អវត្តមាននៃឧស្សាហកម្ម និងសេវាកម្មគាំទ្រ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវ "ផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ ២០២០-២០២៥" ក្នុងគោលដៅជំរុញការងើបឡើងវិញនៃអនុវិស័យនេះ ដោយផ្តោតការយកចិត្តទុកដាក់លើ÷(១). ការធានាអាជីវកម្ម និងសេវាកម្មទេសចរណ៍ដើម្បីអាចរស់រានបន្ត និងត្រៀមខ្លួនសម្រាប់ស្តារ និងលើកកម្ពស់អាជីវកម្មរបស់ខ្លួនឡើងវិញ តាមរយៈការផ្តល់ការគាំទ្រដល់អាជីវកម្មទេសចរណ៍ខ្នាតតូច និងមធ្យម, ការអភិវឌ្ឍជំនាញទេសចរណ៍ និងការជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថល, (២). ការជំរុញទីផ្សារទេសចរណ៍តាមរយៈយុទ្ធនាការផ្សព្វផ្សាយបង្កើនភាពជឿជាក់កម្ពុជាជាគោលដៅសុវត្ថិភាព, ការរៀបចំ travel bubble ក្នុងតំបន់ និងការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង (៣). ការរៀបចំ និងអនុវត្តយន្តការអភិបាលកិច្ចទេសចរណ៍ តាមរយៈការបង្កើតអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តាមរាជធានី-ខេត្ត និងគោលដៅទេសចរណ៍សំខាន់ៗ និងការជំរុញការដាក់ចេញ និងអនុវត្តផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ទេសចរណ៍កម្ពុជា (២០២១-២០៣៥) និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប (២០២១-២០៣៥), ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥) និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប (២០២១-២០៣៥) ។

**២៤.** អនុវិស័យលក់ដុំ-រាយ ត្រូវបានព្យាករថានឹងកើនឡើងវិញក្រោមនិន្នាការទាបជាងធម្មតា ពោលគឺក្នុងអត្រា ៣,២% ក្នុងឆ្នាំ ២០២១ និង ៤,៦% ក្នុងឆ្នាំ ២០២២ ដោយសារការងើបឡើងវិញ នៃភ្ញៀវទេសចរអន្តរជាតិ និងតម្រូវការប្រើប្រាស់ក្នុងស្រុក ស្របនឹងនិន្នាការកំណើននៃអនុវិស័យផ្សេងៗក្នុងសេដ្ឋកិច្ចជាតិ ។ ទោះជាយ៉ាងនេះក្តី, ការបន្តអូសបន្លាយនៃវិបត្តិជំងឺកូវីដ-១៩ នៅតែជាហានិភ័យដល់អនុវិស័យនេះ ដែលអាចបង្កឱ្យមានការធ្លាក់ចុះប្រាក់ចំណូលរបស់ប្រជាជន និងតម្រូវការប្រើប្រាស់ក្នុងស្រុក ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តតាមដាន ក៏ដូចជាប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ ព្រមទាំងដាក់ចេញនូវវិធានការ ដើម្បីរក្សាលំនឹងសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ សំដៅធានានិរន្តរភាពការងារ និងចំណូល ជាពិសេសការបន្តអនុវត្តកម្មវិធីជំនួយសង្គម ដូចជា ឧបត្ថម្ភប្រាក់ជូនកម្មករ-និយោជិត, ឧបត្ថម្ភសាច់ប្រាក់ជូនដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះ និងកម្មវិធីសាច់ប្រាក់ពលកម្ម ។

**២៥.** អនុវិស័យអចលនទ្រព្យ ដែលមាននិន្នាការស្រដៀងគ្នាទៅនឹងអនុវិស័យសំណង់ ត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រាកំណើនទាប ២,៧% ក្នុងឆ្នាំ ២០២១ និង ៤,៨% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកការនូវកើនឡើងយឺតនៃលំហូរទុនវិនិយោគពីបរទេស ខណៈការវិនិយោគ និងតម្រូវការក្នុងស្រុក លើអចលនទ្រព្យដែលមានថ្លៃទាប និងមធ្យមត្រូវបានរំពឹងថានឹងបន្តរក្សាកំណើនល្អប្រសើរ ។ យ៉ាងណាមិញ, ការរឹតត្បិតលំហូរទុនវិនិយោគពីប្រទេសចិន ត្រូវបានរំពឹងថានឹងក្លាយជាហានិភ័យមួយគួរឱ្យកត់សម្គាល់ ដែលអាចទាញកំណើននៃអនុវិស័យនេះមិនអាច

សម្រេចបានតាមការរំពឹងទុក ។ បន្ថែមពីនេះទៀត ទំនាក់ទំនងខ្ពស់រវាងអនុវិស័យនេះ និងវិស័យហិរញ្ញវត្ថុ ក៏បង្កជាក្តីបារម្ភចំពោះលទ្ធភាពនៃការកើតមានវិបត្តិហិរញ្ញវត្ថុ ដែលនឹងអាចជះឥទ្ធិពលអវិជ្ជមានត្រឡប់ទៅអនុវិស័យអចលនទ្រព្យនេះវិញ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តតាមដានអនុវិស័យនេះប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ និងដាក់ចេញនូវវិធានការអន្តរាគមន៍ក្នុងពេលចាំបាច់ សំដៅបញ្ចៀសនូវហានិភ័យដែលអាចកើតឡើងជាយថាហេតុ ។

**២៦.** អនុវិស័យដឹកជញ្ជូននិងគមនាគមន៍ ត្រូវបានព្យាករថានឹងមានកំណើន ៤,៥% ក្នុងឆ្នាំ ២០២១ និង ៥,៩% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកការងើបឡើងវិញនៃអនុវិស័យគាំទ្រសំខាន់ៗ រួមមាន អនុវិស័យកាត់ដេរ, សំណង់ និងសណ្ឋាគារនិងភោជនីយដ្ឋាន និងការកើនឡើងខ្លាំងនៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ដោយសារការផ្លាស់ប្តូរឥរិយាបថនៃការរស់នៅ, ការធ្វើអាជីវកម្ម និងការបំពេញការងារ ជាដើម ។ ទោះជាយ៉ាងនេះក្តី អនុវិស័យនេះនៅបន្តប្រឈមនឹងបញ្ហាមួយចំនួនដូចជា ភាពទន់ខ្សោយនៃប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទិក ខណៈការរៀបចំផែនការមេគ្រប់ជ្រុងជ្រោយនៃវិស័យនេះ មិនទាន់បានបញ្ចប់នៅឡើយ ។ ជាមួយគ្នានេះដែរ, សេវាអ៊ីនធឺណិតនៅមានថ្លៃខ្ពស់ ខណៈគុណភាពសេវា និងបណ្តាញគ្របដណ្តប់នៅមានកម្រិត ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងដោះស្រាយបញ្ហាប្រឈមទាំងនេះ តាមរយៈការពន្លឿនការរៀបចំ និងដាក់ចេញនូវ "ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងឡូជីស្ទិក ២០២១-២០៣០", "ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥" ព្រមទាំងជំរុញការអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (public-private partnership) ដើម្បីគាំទ្រការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។

**តារាងទី ១៖ កំណើនសេដ្ឋកិច្ចតាមវិស័យ**

| កំណើន (%) | ២០២០ ប៉ាន់ | ២០២១ ព្យា. | ២០២២ ព្យា. |
|---|---|---|---|
| **កំណើន ផសស** | **-៣,១%** | **៤,០%** | **៥,៧%** |
| **វិស័យកសិកម្ម** | **០,៥%** | **១,៣%** | **១,១%** |
| ដំណាំ | ០,១% | ១,៦% | ១,២% |
| នេសាទ | ០,៨% | ១,៥% | ១,៤% |
| ការចិញ្ចឹមសត្វ | ១,៩% | ០,៦% | ០,៨% |
| ព្រៃឈើ | -១,២% | -១,៤% | -១,៦% |
| **វិស័យឧស្សាហកម្ម** | **-១,២%** | **៥,៩%** | **៨,២%** |
| កាត់ដេរ | -៦,៤% | ៤,៦% | ៦,០% |
| សំណង់ | -២,៤% | ២,៩% | ៧,៨% |
| កម្មន្តសាលមិនមែនកាត់ដេរ | ១៣,១% | ១២,៥% | ១២,៧% |
| **វិស័យសេវាកម្ម** | **-៦,៧%** | **៣,៤%** | **៥,១%** |

| | | | |
|---|---|---|---|
| សណ្ឋាគារនិងភោជនីយដ្ឋាន | -៣៦,០% | ០,៣% | ៤,៨% |
| លក់ដុំ-រាយ | -៦,៥% | ៣,២% | ៤,៦% |
| អចលនទ្រព្យ | -៤,៩% | ២,៧% | ៤,៨% |
| ដឹកជញ្ជូននិងគមនាគមន៍ | -០,៥% | ៤,៥% | ៥,៩% |

ប្រភព÷ ការប៉ាន់ស្មាន និងការព្យាករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែ មករា ឆ្នាំ ២០២១

**២៧.** ជាមួយគ្នានេះ ក្នុងឆ្នាំ ២០២១ និង ២០២២ អតិផរណាត្រូវបានព្យាករថានឹងកើនឡើងបន្តិច ប៉ុន្តែស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ក្នុងអត្រា ៣,១% និង ៣,០% រៀងគ្នា ដោយសារការកើនឡើងនៃថ្លៃដឹកជញ្ជូន ក្រោមការរំពឹងទុកការងើបឡើងវិញនៃនិន្នាការថ្លៃប្រេងលើទីផ្សារអន្តរជាតិ បន្ទាប់ពីតម្រូវការ និងសកម្មភាពផលិតកម្មសកលមានការកើនឡើងវិញ ។ ដោយឡែក ថ្លៃម្ហូបអាហារ និងផលិតផលផ្សេងទៀតនៅលើទីផ្សារ ត្រូវបានរំពឹងថានឹងកើនឡើងក្នុងអត្រាទាបជាងឆ្នាំ ២០២០ ដោយសារការកែសម្រួលផលិតកម្ម និងខ្សែច្រវាក់ផ្គត់ផ្គង់ ដើម្បីធ្វើថ្លៃឱ្យត្រឡប់ទៅរកនិន្នាការធម្មតាវិញ ។

**២៨.** ស្របពេលជាមួយគ្នានេះដែរ អត្រាប្តូរប្រាក់ត្រូវបានរំពឹងថាមានស្ថិរភាព ក្នុងរង្វង់ ៤ ០៦៥ រៀលក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ ២០២១ និង ២០២២ ដោយសារអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ និងទំនុកចិត្តពីសាធារណជនលើការប្រើប្រាស់ប្រាក់រៀល ។

**២៩. ឱនភាពគណនីចរន្ត** (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងកើនឡើងដល់ទំហំ ១៤,៧% នៃ ផសស ក្នុងឆ្នាំ ២០២១ ធៀបនឹង ៦,៦% នៃ ផសស ក្នុងឆ្នាំ ២០២០ ជាមួយនឹងការរំពឹងទុកការកើនឡើងនៃការនាំចូល ដោយសារការងើបឡើងវិញនូវសកម្មភាពប្រើប្រាស់ក្នុងស្រុក និងសកម្មភាពសេដ្ឋកិច្ចជារួម ។ យ៉ាងណាមិញ, ក្នុងឆ្នាំ ២០២២ ឱនភាពគណនីចរន្តត្រូវបានរំពឹងថានឹងរួមតូចបន្តិចមកវិញមកត្រឹមអត្រា ១២,៨% នៃ ផសស ដោយសារការរំពឹងទុកការកើនឡើងនៃការនាំចេញ និងនិន្នាការងើបឡើងវិញនៃភ្ញៀវទេសចរអន្តរជាតិ ។ ជាមួយគ្នានេះ វំហូរទុនវិនិយោគបរទេសត្រូវបានព្យាករថានឹងកើនឡើងវិញ ដល់ ១២,០% នៃ ផសស ក្នុងឆ្នាំ ២០២១ និង ១២,៣% នៃ ផសស ក្នុងឆ្នាំ ២០២២ ស្របជាមួយការងើបឡើងវិញនូវទំនុកចិត្ត និងសកម្មភាពវិនិយោគសកល ។ ជាលទ្ធផល **ទុនបម្រុងអន្តរជាតិសរុប** ត្រូវរំពឹងថានឹងបន្តកើនឡើងដល់ ២១ ៦១៧ លានដុល្លារអាមេរិក និង ២២ ១១៨ លានដុល្លារអាមេរិក ដែលធានាការនាំចូលបាន ១០,៩ ខែ និង ១០,១ ខែ ក្នុងឆ្នាំ ២០២១ និងឆ្នាំ ២០២២ រៀងគ្នា។

**តារាងទី ២÷ តារាងប៉ាន់ស្មានទំហំពាណិជ្ជកម្ម និងវិនិយោគផ្ទាល់ពីបរទេស**

| សូចនាករ | ២០២០ ប៉ាន់ | ២០២១ ព្យា. | ២០២២ ព្យា. |
|---|---|---|---|
| ការនាំចេញ (លានដុល្លារអាមេរិក) | ១៧ ៣៤៣ | ១៦ ៦០៤ | ១៨ ៣៥៦ |
| ការនាំចូល (លានដុល្លារអាមេរិក) | ២០ ១៦៥ | ២១ ៧៩០ | ២៣ ៩១៩ |
| ឱនភាពគណនីចរន្ត (លានដុល្លារអាមេរិក) | ១ ៧៦៦ | ៤ ២២៤ | ៤ ០១២ |
| វំហូរទុនវិនិយោគបរទេស (លានដុល្លារអាមេរិក) | ៣ ១៣៣ | ៣ ៤៥២ | ៣ ៨៥៨ |

| | | | |
|---|---|---|---|
| ការនាំចេញ (ភាគរយនៃ ផសស) | ៦៤,៩% | ៥៧,៨% | ៥៨,៧% |
| ការនាំចូល (ភាគរយនៃ ផសស) | ៧៥,៤% | ៧៥,៩% | ៧៦,៥% |
| ឱនភាពសមតុល្យពាណិជ្ជកម្មសរុប (ភាគរយនៃ ផសស) | ១០,៦% | ១៨,១% | ១៧,៨% |
| ឱនភាពគណនីចរន្ត (ភាគរយនៃ ផសស) | ៦,៦% | ១៤,៧% | ១២,៨% |
| វិហូរទុនវិនិយោគបរទេស (ភាគរយនៃ ផសស) | ១១,៧% | ១២,០% | ១២,៣% |

ប្រភព÷ ធនាគារជាតិនៃកម្ពុជា និងការព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែមករា ឆ្នាំ ២០២១

**៣០.** បើទោះបីជាសេដ្ឋកិច្ច ក្នុងឆ្នាំ ២០២២ ត្រូវបានរំពឹងថានឹងងើបឡើងវិញក្នុងអត្រាកំណើនខាងលើក៏ដោយ, កម្ពុជាក៏នៅប្រឈមនឹងការកើនឡើងនៃហានិភ័យ រួមមាន÷

(១)- ការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ និងការបំប្លែងខ្លួនថ្មីនៃវីរុសក្លាយណា (new variants) ព្រមទាំងការ-អូសបន្លាយនៃការឆ្លងក្នុងសហគមន៍ទ្រង់ទ្រាយធំក្នុងស្រុក,

(២)- ការថមថយវិហូរទុនវិនិយោគពីបរទេស,

(៣)- ការកើតមានវិបត្តិហិរញ្ញវត្ថុសកលក្រោយវិបត្តិជំងឺកូវីដ-១៩,

(៤)- ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចសកលជាងការរំពឹងទុក បង្កឡើងដោយភាពតានតឹងនៃភូមិសាស្ត្រនយោបាយ និងសន្តិសុខតំបន់ និងសកល និងភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យា,

(៥)- វិបត្តិសកលធ្ងន់ធ្ងរ (global depression) បង្កឡើងដោយការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក,

(៦)- ភាពមិនប្រាកដប្រជានៃប្រព័ន្ធអនុគ្រោះពន្ធ និង

(៧)- ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ

**៣១.** ទន្ទឹមនឹងការកើនឡើងនៃហានិភ័យខាងលើ, កម្ពុជានៅតែបន្តប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធមួយចំនួន រួមមាន÷

(១)- ល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច,

(២)- ថ្លៃដើមធ្វើធុរកិច្ចនៅមានកម្រិតខ្ពស់,

(៣)- ភាពមានកម្រិតនៃកិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ចទូទៅ,

(៤)- បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញដែលមិនទាន់អាចឆ្លើយតបនឹងតម្រូវការទីផ្សារ,

(៥)- ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម និង

(៦)- ភាពមានកម្រិតនៃចំណេះដឹង និងជំនាញ (skills) ក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល ។

**៣២.** ក្នុងឆ្នាំ ២០២២ រាជរដ្ឋាភិបាលនឹងផ្តោតលើការជំរុញការកែទម្រង់ជារចនាសម្ព័ន្ធ និងជាប្រព័ន្ធ ព្រម-ទាំងពង្រឹងការកសាងភាពធន់នៃសេដ្ឋកិច្ច និងសង្គម ឱ្យកាន់តែរឹងមាំ និងមានភាពឆ្លើយតបខ្ពស់ ដោយផ្តោតលើអាទិ-ភាព ៤ រួមមាន÷

**ការពង្រឹងរដ្ឋបាលសាធារណៈ** តាមរយៈការកែទម្រង់ស្ថាប័នរដ្ឋ និងពង្រឹងសមត្ថភាពដឹកនាំ ព្រមទាំងការលើកកម្ពស់ភាពម្ចាស់ការ និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន ដើម្បីឈានទៅសម្រេចបានរដ្ឋបាលសាធារណៈស្អាតស្អំ ឆ្លាតវៃ និងមានសមត្ថភាពខ្លាំងពូកែ ។

**ការកសាងភាពធន់នៃសេដ្ឋកិច្ច** តាមរយៈការពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការលើកកម្ពស់ភាពប្រកួតប្រជែង ដោយផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម, ការជំរុញឌីជីថលូបនីយកម្មក្នុងប្រព័ន្ធសេដ្ឋកិច្ច ទាំងវិស័យសាធារណៈ និងវិស័យឯកជន និងការកសាងហេដ្ឋារចនាសម្ព័ន្ធគុណភាពខ្ពស់, ហេដ្ឋារចនាសម្ព័ន្ធបៃតង និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ។

**ការកសាងភាពធន់ផ្នែកសង្គម** ដោយផ្តោតលើការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ទាំងគុណភាព និងវិសាលភាព ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងវិបត្តិ ឬហានិភ័យនានា ដែលអាចកើតឡើងជាយថាហេតុនាពេលអនាគត ព្រមទាំងការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពនៃវិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ការកសាងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ** ដោយពង្រឹងសមត្ថភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុក្នុងការសម្របខ្លួន និងឆ្លើយតបទៅនឹងការប្រែប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គម ដើម្បីបំពេញតួនាទីស្នូលក្នុងការគាំទ្រសកម្មភាពសេដ្ឋកិច្ចទាំងមូល ។ ការកសាងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ ត្រូវធ្វើឡើងតាមរយៈការបន្តធ្វើពិពិធកម្មផលិតផលហិរញ្ញវត្ថុ, អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធហិរញ្ញវត្ថុ ជាពិសេសបច្ចេកវិទ្យាហិរញ្ញវត្ថុ, ម្យ៉ាងពង្រឹងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ គឺធ្វើទំនើបកម្ម និងវិចារណៈកម្មប្រព័ន្ធពន្ធនានា, ប្រព័ន្ធគ្រប់គ្រងចំណាយថវិកា និងការគ្រប់គ្រងបំណុលសាធារណៈឱ្យមានប្រសិទ្ធភាព និងចីរភាព ព្រមទាំងកសាងប្រាក់សន្សំរបស់រដ្ឋសម្រាប់ធ្វើអន្តរាគមន៍ក្នុងពេលមានវិបត្តិ និងម្យ៉ាងទៀត, ពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងប្រព័ន្ធឆ្លើយតបនឹងវិបត្តិរបស់ធនាគារ ជាដើម ។ ទន្ទឹមនេះ សំណាញ់សុវត្ថិភាពហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សានូវស្ថិរភាពហិរញ្ញវត្ថុ និងពង្រឹងភាពធន់ក្នុងការឆ្លើយតបនឹងវិបត្តិនាពេលអនាគត ។ ការពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុនឹងរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវការតាមដាន និងឃ្លាំមើលម៉ាក្រូសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ, ពង្រឹងការគ្រប់គ្រងវិបត្តិ និងសហប្រតិបត្តិការក្នុងការធានាស្ថិរភាព និងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ ។

## ៤. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

៣៣. ក្នុងបរិការណ៍ដែលវិបត្តិជំងឺកូវីដ-១៩ នៅតែបន្តអូសបន្លាយ និងជះឥទ្ធិពលអវិជ្ជមានមកលើសង្គម និងសេដ្ឋកិច្ចកម្ពុជា, ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ផ្តល់អាទិភាពខ្ពស់បំផុតដល់ចំណាយចាំបាច់នានា ក្នុងការទប់ទល់ការរាតត្បាត និងកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បន្តផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍវិស័យអាទិភាពផ្សេងទៀត ព្រមជាមួយនឹងការតម្រង់ធនធានសំដៅជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ នៅក្រោយពេលស្រាកស្រាន្តពីវិបត្តិជំងឺកូវីដ-១៩ ។

៣៤. ជាមួយគ្នានេះ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២២ ដែលត្រូវបានរៀបចំឡើង ដោយផ្អែកលើមូលដ្ឋានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល មានគោលបំណងដូចខាងក្រោម៖

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ,
- ធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលមធ្យម,
- ជំរុញកំណែទម្រង់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា,
- បន្តដាក់ចេញក្របខ័ណ្ឌចំណាយអន្តរាគមន៍សង្គម-សេដ្ឋកិច្ច សំដៅការពារអាយុជីវិត និងសុខភាពរបស់ប្រជាជន ព្រមទាំងធានារក្សាលំនឹងសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងដោះស្រាយផលប៉ះពាល់នានាដែលនៅសេសសល់ពីវិបត្តិជំងឺកូវីដ-១៩,
- បន្តអនុវត្តគោលនយោបាយអាទិភាពលើផ្នែកគាំពារសង្គម និងបង្កើនគុណភាពសេវាសុខាភិបាល ព្រមទាំងជំរុញការអភិវឌ្ឍប្រព័ន្ធសុខភាពសាធារណៈ និងប្រព័ន្ធគាំពារសង្គម ដើម្បីអាចឆ្លើយតបនឹងគ្រោះអាសន្នជាយថាហេតុ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ,
- បន្តតម្រង់ទិសធនធានទៅអភិវឌ្ឍវិស័យអាទិភាព ក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ ដូចជា វិស័យកសិកម្ម, វិស័យទេសចរណ៍, វិស័យឌីជីថល និងវិស័យកម្មន្តសាលថ្មីៗ ដើម្បីជំរុញការងើបឡើងនៃកំណើនសេដ្ឋកិច្ច និងពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច,
- បន្តគាំទ្រការអភិវឌ្ឍវិស័យឯកជន និងសហគ្រាសធុនតូច និងមធ្យម តាមរយៈការដាក់ចេញនូវវិធានការលើកទឹកចិត្តជាក់លាក់, ការបង្កភាពងាយស្រួលក្នុងការធ្វើធុរកិច្ច (ease of doing business) ដើម្បីធ្វើឱ្យរស់រវើកឡើងវិញនូវសកម្មភាពអាជីវកម្មក្នុងស្រុក និងការបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានកម្ចីការប្រាក់ទាប,
- បន្តលើកកម្ពស់វិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគុណភាពខ្ពស់, ហេដ្ឋារចនាសម្ព័ន្ធបៃតង និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល សំដៅជំរុញការតភ្ជាប់ក្នុងសេដ្ឋកិច្ច, ការអភិវឌ្ឍប្រកបដោយចីរភាព និងការធ្វើបរិវត្តកម្មឌីជីថលនៅកម្ពុជា,
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឱ្យបានគ្រប់គ្រាន់ ស្របតាមតម្រូវការទីផ្សារ និងប្រក្រតីភាពថ្មី,
- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង

- បន្តគិតគូរដំឡើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងកម្រិតសមស្រប ដោយផ្អែកលើសមិទ្ធកម្ម ឬគុណាធិបតេយ្យ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន និងគុណភាពនៃការផ្តល់សេវាសាធារណៈ ។

**៣៥.** ជារួម ដើម្បីធានាឱ្យសេដ្ឋកិច្ចកម្ពុជាអាចបន្តដំណើរលើគន្លងកំណើនប្រកបដោយបរិយាបន្ន និងភាពធន់, ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២២ ត្រូវបានរៀបចំឡើងដោយមានចរិតជា **គោលនយោបាយវិក្តារកម្មថវិកា** ដែលរាជរដ្ឋាភិបាលនឹងបន្តអនុវត្តនូវកញ្ចប់វិធានការអន្តរាគមន៍សង្គម-សេដ្ឋកិច្ច សំដៅធានា និងបង្កើតការងារជូនប្រជាពលរដ្ឋ ព្រមទាំងលើកកម្ពស់ធុរកិច្ចក្នុងស្រុក តាមរយៈការផ្តល់ការលើកទឹកចិត្ត និងបង្កើនទំនុកចិត្តវិនិយោគិន, បន្តអភិវឌ្ឍធនធានមនុស្ស, លើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ និងបន្តដោះស្រាយរាល់បញ្ហាប្រឈមជារចនាសម្ព័ន្ធនានា ដែលជំរុញពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់ភាពប្រកួតប្រជែង ។ ក្របខ័ណ្ឌនេះត្រូវបានគិតគូរប្រកប ដោយភាពប្រុងប្រយ័ត្នខ្ពស់ ដោយថ្លឹងថ្លែងរវាងលទ្ធភាពក្នុងការប្រមូលចំណូល គួបផ្សំនិងលទ្ធភាពក្នុងការកៀរគរ និងបង្កើនហិរញ្ញប្បទានផ្សេងៗ រាប់បញ្ចូល ហិរញ្ញប្បទានក្រៅប្រទេស និងទំហំតម្រូវការចំណាយដែលនៅតែបន្តកើនឡើង ដើម្បីគាំទ្រចលនការនៃកំណើនសេដ្ឋកិច្ច និងធានាសម្រេចឱ្យបាននូវកិច្ចការអាទិភាពរបស់រាជរដ្ឋាភិបាល ខណៈរក្សាតុល្យភាពថវិកាស្ថិតក្នុងកម្រិតសមស្រប ដែលធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ។

**៣៦.** ការប្រមូលចំណូលឆ្នាំ ២០២២ ត្រូវបានរំពឹងទុកថានឹងមានកំណើនខ្ពស់ជាងឆ្នាំ ២០២១ ដោយសារសកម្មភាពសេដ្ឋកិច្ចកាន់តែមានភាពប្រសើរឡើង ។ យ៉ាងណាមិញ, សម្រាប់រយៈពេលខ្លី និងមធ្យមខាងមុខ ការប្រមូលចំណូលអាចជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជា÷ (១). ចំណូលសារពើពន្ធអាចប្រឈមនឹងកំណើនទាប ដោយសារ ការងើបឡើងវិញយឺតនៃកំណើនសេដ្ឋកិច្ច ទន្ទឹមនឹងការគិតគូរដាក់ចេញនូវវិធានការគោលនយោបាយអនុគ្រោះពន្ធ ដើម្បីលើកទឹកចិត្តសកម្មភាពធុរកិច្ច, ជំរុញផលិតកម្មក្នុងស្រុក, ទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងគាំទ្រការអភិវឌ្ឍវិស័យអាទិភាព និង (២). ចំណូលមិនមែនសារពើពន្ធ នៅមិនទាន់ប្រមូលឱ្យអស់សក្តានុពលនៅឡើយ ដោយសារភាពនៅមានកម្រិតនៃប្រសិទ្ធភាពក្នុងការគ្រប់គ្រង ជាពិសេសអវត្តមាននៃបទប្បញ្ញត្តិគោល, លិខិតបទដ្ឋានគតិយុត្តគាំទ្រ និងភាពមានកម្រិតនៃប្រព័ន្ធសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជាការកៀរគរចំណូលមិនទាន់អស់លទ្ធភាពពីប្រភពដែលមានសក្តានុពល ដូចជា វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍, វិស័យរ៉ែ និងថាមពល, កិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ និងសម្បទានដីសេដ្ឋកិច្ចជាដើម ។

**៣៧.** ទន្ទឹមនេះ ក្របខ័ណ្ឌចំណាយសាធារណៈឆ្នាំ ២០២២ ត្រូវបានរៀបចំដើម្បីគាំទ្រដល់ការបន្តងើបឡើងវិញនៃសេដ្ឋកិច្ច ដោយឈរលើគោលការណ៍លើកកម្ពស់ប្រសិទ្ធភាពចំណាយទាំងក្នុងកម្រិតវិភាជន៍ និងប្រតិបត្តិការ ព្រមទាំងរឹតបន្តឹងចំណាយមិនចាំបាច់ផ្សេងៗ ដើម្បីតម្រង់ទិសនៃការបែងចែក និងប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយស័ក្តិសិទ្ធិភាព ។ ក្របខ័ណ្ឌនេះក៏ត្រូវបានគិតគូរលើការកសាងភាពធន់នៃសង្គម-សេដ្ឋកិច្ច ដោយបន្តលើកកម្ពស់គុណភាពប្រព័ន្ធសុខាភិបាល, រៀបចំប្រព័ន្ធគាំពារសង្គមឱ្យមានការឆ្លើយតបខ្ពស់ទៅនឹងគ្រោះអាសន្ន, បន្តពង្រឹងគុណភាព និងពង្រីកវិសាលភាពនៃការផ្តល់សេវាសាធារណៈ, លើកកម្ពស់បរិយាកាសធុរកិច្ច និងលើកទឹកចិត្តដល់សកម្មភាព

សេដ្ឋកិច្ចក្នុងស្រុក ព្រមទាំងជំរុញការវិនិយោគលើជំនាញ តាមរយៈវគ្គបណ្តុះបណ្តាលជំនាញថ្មី និងការបង្កើនចំណេះដឹងបន្ថែម (reskilling and upskilling) និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគុណភាពខ្ពស់, ហេដ្ឋារចនាសម្ព័ន្ធបៃតង និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ។

**៣៨.** ដូចនេះ ដើម្បីឈានទៅសម្រេចគោលបំណងនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ, រាជរដ្ឋាភិបាល កំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២២ ដូចខាងក្រោម÷

- ចំណូលក្នុងស្រុកសរុបត្រូវបានគ្រោងប្រមាណ ២១,៤៧%នៃ ផសស ក្នុងនោះ÷
  - ចំណូលចរន្តត្រូវបានគ្រោងសម្រេចឱ្យបានក្នុងទំហំ ២១,២៨% នៃ ផសស និងមានកំណើន ១១,៧% ធៀបនឹងការប៉ាន់ស្មានចំណូលចរន្តក្នុងឆ្នាំ ២០២១ ឬ ២៧,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២១ ដែលក្នុងនោះ ថ្នាក់ជាតិត្រូវគ្រោងសម្រេចឱ្យបានប្រមាណ ១៩,២៥% នៃ ផសស និងថ្នាក់ក្រោមជាតិ ២,០៣% នៃ ផសស ។
  - សម្រាប់ការប្រមូលចំណូលតាមអគ្គនាយកដ្ឋាន÷ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន ៩,០៣% នៃ ផសស, អគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន ១០,០៨% នៃ ផសស និង ចំណូលមិនមែនសារពើពន្ធ ត្រូវគ្រោងសម្រេចឱ្យបាន ២,១៧% នៃ ផសស ។
  - ចំណូលមូលធនក្នុងស្រុកក្នុងត្រូវគ្រោងសម្រេចឱ្យបានប្រមាណ ០,១៩% នៃ ផសស ។
- ចំណាយសរុបថវិការដ្ឋត្រូវបានគ្រោងក្នុងរង្វង់ ២៩,២៣% នៃ ផសស ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៧,២០% នៃ ផសស និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ២,៩១% នៃ ផសស ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិចំនួន ០,៨៨% នៃ ផសស ។
  - ចំណាយចរន្តថវិការដ្ឋត្រូវបានគ្រោងក្នុងរង្វង់ ១៦,៨១% នៃ ផសស ដែលក្នុងនោះ ចំណាយបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៤៨,៤% នៃចំណាយចរន្តសរុប ត្រូវជា ៨,១៤% នៃ ផសស និង ចំណាយក្រៅបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៥១,៦% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៨,៦៧% នៃ ផសស ។
  - ចំណាយមូលធនត្រូវបានគ្រោងក្នុងរង្វង់ ១២,៤១% នៃ ផសស ដែលក្នុងនោះ ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានគ្រោងក្នុងរង្វង់ ៦,៦៧% នៃ ផសស និង ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងក្នុងរង្វង់ ៤,៥៨% នៃ ផសស ។

**៣៩.** ចំណាយថ្នាក់ជាតិ ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេសសម្រាប់ឆ្នាំ ២០២២ ត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចខាងក្រោម÷

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៧៩% នៃ ផសស សំដៅបន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងការងារការទូតជាពិសេស ការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ ២០២១-២០២៣, ការអនុវត្តច្បាប់ស្តីពីវិនិយោគ



8

នៃព្រះរាជាណាចក្រកម្ពុជា, ការរៀបចំដំណើរការបោះឆ្នោតឃុំ- សង្កាត់ឆ្នាំ ២០២២ និងការត្រៀមរៀបចំបោះឆ្នោតថ្នាក់ជាតិឆ្នាំ ២០២៣ ។

- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ៤,១៨% នៃ ផសស ដែលនឹងបន្តផ្តោតលើ ការគាំទ្រការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការលើកកម្ពស់សុខុមាលភាព និងពង្រឹងសមត្ថភាពរបស់កងកម្លាំងប្រដាប់អាវុធ ក្នុងបុព្វហេតុធានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ ។
- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៧,០៤% នៃ ផសស សំដៅបន្តជំរុញ និងគាំទ្រការអនុវត្តគោលនយោបាយ, យុទ្ធសាស្ត្រ និងផែនការសកម្មភាពគន្លឹះ មានជាអាទិ៍÷ ការលើកកម្ពស់គុណភាព និងការពង្រីកវិសាលភាពការទទួលបានសេវាសុខាភិបាល, ការពង្រឹងប្រព័ន្ធសុខភាពសាធារណៈដែលឆ្លើយតបនឹងគ្រោះអាសន្ននាពេលអនាគត, ផែនការមេសម្រាប់ឆ្លើយតបទៅនឹងជំងឺកូវីដ-១៩, គោល-នយោបាយជាតិគាំពារសង្គម ជាពិសេសកម្មវិធីជួយដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះ, ការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស និង គោលនយោបាយអាទិភាពផ្សេងទៀតលើផ្នែកសង្គមកិច្ច សាសនា វប្បធម៌ និងបរិស្ថាន ។
- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៨,៥៩% នៃ ផសស ដែលជំរុញ និងគាំទ្រការអនុវត្ត គោល-នយោបាយ, យុទ្ធសាស្ត្រ និងផែនការសកម្មភាពគន្លឹះ មានជាអាទិ៍÷ ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម តាមរយៈការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ២០២១-២០២៦, ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងឡូជីស្ទីក ២០២១-២០៣០, យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ ២០២០-២០៣០, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ និងការបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា ។ លើសពីនេះ ក៏ជំរុញការអនុវត្តផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ ២០២០-២០២៥ និង ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប (២០២១-២០៣៥) ។
- **ចំណាយផ្សេងៗ** ត្រូវបានគ្រោងក្នុងទំហំ ៥,៦១% នៃ ផសស ដើម្បីត្រៀមបម្រុងសម្រាប់ការអនុវត្តគោលនយោបាយនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, ការវិភាជកញ្ចប់ថវិកាសម្រាប់ការរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ, និងកិច្ចការបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាល ដូចជាការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយធម្មជាតិ កិច្ចការអធិបតេយ្យ និងស្បៀងបម្រុង ជាដើម ។

៤០. ដោយឈរលើមូលដ្ឋានក្របខ័ណ្ឌចំណូល និងចំណាយខាងលើ, **អតិរេកថវិកាចរន្ត** សម្រាប់ឆ្នាំ ២០២២ នឹងស្ថិតក្នុងរង្វង់ ៤,៤៦% នៃ ផសស និង**ឱនភាពថវិកាសរុប** ស្ថិតក្នុងរង្វង់ ៧,៧៦% នៃ ផសស *(សូមពិនិត្យក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២០-២០២៤ ក្នុងឧបសម្ព័ន្ធ ២ ភ្ជាប់មកជាមួយ)* ។

៤១. ដើម្បីធានាបាននូវការអនុវត្តតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, ក្របខ័ណ្ឌថវិកាក្នុងឆ្នាំ ២០២២ និងឆ្នាំបន្តបន្ទាប់ ត្រូវរៀបចំឡើងឈរលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការ ដូចខាងក្រោម÷

**៤.១. វិធានការផ្នែកចំណូល**

៤២. វិធានការផ្នែកចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធសម្រាប់ឆ្នាំ ២០២២ ត្រូវបានរៀបចំដោយគិតគូរលើការបន្តដាក់ចេញនូវគោលនយោបាយលើកទឹកចិត្ត ឬអនុគ្រោះបន្ថែមដល់អាជីវកម្មក្នុងស្រុក ខណៈធានាឱ្យបាននូវចីរភាពចំណូល ។ ដោយផ្អែកលើសូចនាករគន្លឹះជាអាទិភាពក្នុង យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ និងគោលនយោបាយអាទិភាពក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩ វិធានការជាក់លាក់ត្រូវបានកំណត់ រួមមាន÷

**ក. វិធានការផ្នែកពន្ធដារ**

៤៣. វិធានការគន្លឹះសម្រាប់អនុវត្តក្នុងឆ្នាំ ២០២២ ដើម្បីគាំទ្រសកម្មភាពនៃអាជីវកម្មក្នុងស្រុក និងរក្សាចីរភាពកំណើនចំណូល ដែលនឹងត្រូវអនុវត្តដោយអគ្គនាយកដ្ឋានពន្ធដារ រួមមាន÷

- បន្តអនុវត្តគោលនយោបាយលើកទឹកចិត្ត និងដាក់ចេញនូវវិធានការថ្មីៗចាំបាច់បន្ថែមទៀត ដល់វិស័យដែលបន្តរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ សំដៅទ្រទ្រង់និងស្តារអាជីវកម្ម និងធុរកិច្ច ឱ្យងើបឡើងវិញ,
- បន្តពិនិត្យ និងកែតម្រូវអត្រាពន្ធកាត់ទុកលើកម្ចីរបស់ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ គ្រប់ប្រភេទទាំងក្នុង និងក្រៅស្រុក ស្របតាមការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច និងវិបត្តិជំងឺកូវីដ-១៩,
- ពង្រីកវិសាលភាពនៃការប្រមូលចំណូលពន្ធពាក់ព័ន្ធនឹងអចលនទ្រព្យដោយ÷ (១). ការពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់, (២). ការពង្រីកវិសាលភាពនៃការប្រមូលពន្ធលើអចលនទ្រព្យនៅទីប្រជុំជន, (៣). ការពិនិត្យឡើងវិញការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ, (៤). ការពង្រឹងការបង់ពន្ធប្រថាប់ត្រា ចំពោះការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា តាមច្បាប់ជាធរមាន និង (៥). បន្តរៀបចំយន្តការសម្រាប់ពង្រឹងការអនុវត្តតារាងឧបសម្ព័ន្ធតម្លៃអចលនទ្រព្យថ្មី សម្រាប់ជាមូលដ្ឋានគិតពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ និងពន្ធលើអចលនទ្រព្យ,
- ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធក្នុងវិស័យកម្មន្តសាលផលិតភេសជ្ជៈ ជាពិសេសស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា,

- បន្តជំរុញការចុះបញ្ជីសហគ្រាស និងផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធក្នុងការចុះបញ្ជីពន្ធដារ ដើម្បីបង្កើនមូលដ្ឋានអ្នកជាប់ពន្ធ,
- ពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យ ដោយផ្អែកលើការវិភាគ និងវាយតម្លៃផលប៉ះពាល់វដ្តធុរកិច្ច (business cycle) តាមរយៈការប្រមូល និងវិភាគទិន្នន័យព័ត៌មានអំពីហានិភ័យអនុលោមភាព និងកែសម្រួលឯកសារបច្ចុប្បន្នភាពនៃការវិភាគហានិភ័យទូទៅ,
- ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងពិនិត្យលទ្ធភាព ដើម្បីឈានបង្កើតឱ្យមានមជ្ឈមណ្ឌលរក្សាទិន្នន័យរួម,
- រៀបចំផែនការសវនកម្មប្រចាំឆ្នាំ និងកាត់បន្ថយការធ្វើសវនកម្មជាន់គ្នា (សវនកម្មពេញលេញ និងសវនកម្មមានកម្រិត) ដើម្បីសម្រួលបន្ទុកដល់អ្នកជាប់ពន្ធ និង
- ធ្វើបច្ចុប្បន្នភាព និងកែប្រែទៅជំនាន់ថ្មីលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធឱ្យមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា ។

## ខ. វិធានការផ្នែកគយ

**៤៤.** វិធានការគន្លឹះ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០២២ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នឹងផ្តោតលើគោលដៅជាអាទិភាព ដូចខាងក្រោម ÷

- បន្តអនុវត្តវិធានការលើកទឹកចិត្តពន្ធគយ ព្រមទាំងដាក់ឱ្យអនុវត្តនូវវិធានការបន្ថែម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩,
- កែលម្អគោលនយោបាយពន្ធ និងអាករ សម្រាប់វិស័យអាទិភាព និងមុខទំនិញនានាឱ្យស្របតាមតម្រូវការចាំបាច់ និងការវិវឌ្ឍនៃមុខទំនិញទាំងនោះ,
- ពិនិត្យលទ្ធភាពកែសម្រួលមូលដ្ឋានគិតពន្ធ និងអត្រាអាករពិសេសលើទំនិញដែលមានលក្ខណៈប្រណិត, ប៉ះពាល់បរិស្ថាន និងសុខភាព ក្នុងករណីចាំបាច់,
- បន្តធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីគយ និងកិច្ចប្រតិបត្តិការគយផ្សេងទៀត ស្របតាមស្តង់ដារអន្តរជាតិ សំដៅបង្កើនគុណភាពនៃការផ្តល់សេវា និងភាពពេញចិត្តរបស់អតិថិជន,
- កែសម្រួល និងដាក់ឱ្យអនុវត្តកញ្ចប់ប្រព្រឹត្តកម្មលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពខ្ពស់តាមរយៈ ការផ្តល់ប្រព្រឹត្តកម្មពិសេសក្នុងការបំពេញបែបបទគយ និងបន្តពិនិត្យលទ្ធភាពបង្កើនចំនួនធុរជនល្អបំផុត,
- លើកកម្ពស់ការយល់ដឹងរបស់ធុរជនលើការងារបច្ចេកទេសគយ និងនីតិវិធីនៃការបំពេញបែបបទគយតាមរយៈការផ្សព្វផ្សាយមគ្គុទ្ទេសក៍ និងវគ្គបណ្តុះបណ្តាលអំពីតម្លៃគិតពន្ធគយ, ចំណាត់ថ្នាក់ទំនិញ និងការអនុវត្តអត្រាពន្ធអនុគ្រោះក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ព្រមទាំងនីតិវិធីគយជាធរមាន,

- បន្តពង្រឹងយន្តការ និងពង្រីកបន្ថែមទៀតនូវវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ,
- បន្តពង្រឹងប្រសិទ្ធភាពនៃការបង្ការ និងបង្ក្រាបបទល្មើសគយ តាមរយៈការចុះឃ្លាំមើលតំបន់ភូមិសាស្ត្រដែលមានហានិភ័យខ្ពស់, ការវិភាគព័ត៌មាន និងហានិភ័យ, និងការចែករំលែកព័ត៌មានសម្ងាត់ក្នុងកម្រិតទ្វេភាគី តំបន់ និងសកល,
- ពិនិត្យលទ្ធភាពរៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីគយគ្រប់គ្រងភណ្ឌាគារផលិតកម្មមានដែនកំណត់ ដែលធ្វើប្រតិបត្តិការកែច្នៃ ឬចម្រាញ់តេលសិលាឆៅ ឬប៊ីទីមខនិជ និង
- ជំរុញធ្វើទំនើបកម្ម និងធ្វើសន្ទានកម្មបច្ចេកវិទ្យាព័ត៌មានរបស់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាឱ្យបានកាន់តែទូលាយ ដូចជាប្រព័ន្ធអាស៊ីគូដា, ប្រព័ន្ធបញ្ជរតែមួយជាតិ, ប្រព័ន្ធគ្រប់គ្រងហានិភ័យ, និង direct trader input (DTI) ។

### គ. វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ

**៤៥.** ដើម្បីបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ និងប្រមូលចំណូលពីប្រភពដែលមានសក្តានុពល ក្នុងស្ថានភាពដែលចំណូលមិនមែនសារពើពន្ធបានធ្លាក់ចុះយ៉ាងគំហុក ដោយសារផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩, វិធានការគន្លឹះចាំបាច់ត្រូវបន្តអនុវត្ត រួមមាន÷

- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រ ក្នុងន័យបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការកៀរគរចំណូលឱ្យអស់សក្តានុពល,
- ជំរុញការរៀបចំឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ,
- ជំរុញការរៀបចំក្របខ័ណ្ឌគតិយុត្តថ្មីក្នុងការគ្រប់គ្រងសហគ្រាសសាធារណៈ ឱ្យស្របតាមការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច,
- ជំរុញការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) អនឡាញ នៅតាមក្រសួង-ស្ថាប័ន,
- បន្តអភិវឌ្ឍ និងបន្ថែមមុខងារដល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ដូចជាការផ្តល់វិក្កយបត្រតាមអនឡាញ និងការបង់ចំណូលមិនមែនសារពើពន្ធតាមរយៈការទូទាត់បែបអេឡិចត្រូនិក (e-payment), បន្តធ្វើបច្ចុប្បន្នភាព និងដាក់បញ្ចូលកិច្ចសន្យា កិច្ចព្រមព្រៀង ឬអាជ្ញាបណ្ណ និងជំរុញការប្រើប្រាស់ឱ្យបានទូលំទូលាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ,
- សិក្សា និងពិនិត្យលទ្ធភាពរៀបចំឡើងវិញការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្ម តាមរយៈការបែងចែកតំបន់ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងអភិវឌ្ឍ ស្របតាមសក្តានុពលតំបន់ និងផ្តល់ភាពងាយស្រួលក្នុងការផ្តល់សេវាសាធារណៈ,

- ផ្តល់ការគាំទ្រដល់ការអភិវឌ្ឍរមណីយដ្ឋានដែលមានសក្តានុពល ដើម្បីទាក់ទាញភ្ញៀវទេសចរ និងពង្រឹងការប្រមូលចំណូលឱ្យអស់លទ្ធភាព,
- បន្តដាក់ចេញវិធានការគាំទ្រ ឬអន្តរាគមន៍ ទៅតាមវិស័យដែលរងផលប៉ះទង្គិចពីជំងឺកូវីដ-១៩,
- ពង្រឹងយន្តការគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល,
- ជំរុញ និងពង្រឹងការគ្រប់គ្រងការប្រមូលចំណូលពីធនធានរ៉ែ ដោយអនុវត្តយន្តការបង់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក, ជំរុញការអនុវត្តយន្តការអធិការកិច្ចចំពោះក្រុមហ៊ុន ឬអាជីវកម្ម, ពិនិត្យផ្ទាល់ដល់ទីតាំងឬការដ្ឋានអាជីវកម្ម និងបង្កើនកិច្ចសហប្រតិបត្តិការរវាងក្រសួងទទួលបន្ទុក,
- ពិនិត្យឡើងវិញ និងកែសម្រួលថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច អនុលោមតាមគោលការណ៍ដែលអនុម័តដោយរាជរដ្ឋាភិបាល ដោយតម្រូវឱ្យបង់ថ្លៃឈ្នួលតាមទំហំសម្បទានដីសេដ្ឋកិច្ចដែលទទួលបាន ជាជាងទំហំដីដែលបានធ្វើការឈូសឆាយ,
- រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានសម្រាប់គ្រប់គ្រងអាជ្ញាបណ្ណ និងចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ នៅថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ ឱ្យបានពេញលេញ ក្នុងគោលដៅពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល,
- ពិនិត្យ និងរៀបចំយន្តការស្តង់ដារក្នុងការគ្រប់គ្រង, ការបែងចែក និងការប្រើប្រាស់រង្វាន់ពីសេវាសាធារណៈផ្អែកលើគោលការណ៍សមធម៌ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពប្រមូលចំណូល និង
- បន្តជំរុញការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការបង់ចំណូលតាមប្រព័ន្ធធនាគារតាមរយៈការជំរុញបន្ថែមពេលប្រតិបត្តិករមកបន្តអាជ្ញាបណ្ណ និងការចុះជំរុញតាមទីតាំងអាជីវកម្មផ្ទាល់ ។

### ៤.២ វិធានការផ្នែកចំណាយ

**៤៦.** ដើម្បីទ្រទ្រង់ចលនការនៃការជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ក្នុងបរិការណ៍ដែលវិបត្តិកូវីដ-១៩ នៅតែអាចបន្តអូសបន្លាយ, រាជរដ្ឋាភិបាលនឹងអនុវត្តវិធានការជាក់លាក់ និងមុតស្រួច ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ ២០២២ ដូចខាងក្រោម÷

- បន្តដាក់ចេញនូវកញ្ចប់ថវិកាអន្តរាគមន៍ សំដៅធានាបាននូវលទ្ធភាពក្នុងការបន្តជំរុញកំណើនសេដ្ឋកិច្ច និងដោះស្រាយបញ្ហាដែលនៅបន្តសេសសល់ពីវិបត្តិជំងឺកូវីដ-១៩,
- តម្រង់ធនធានថវិកាលើវិស័យគន្លឹះ ដែលនឹងធានាឱ្យបានភាពធន់ ប្រកបដោយបរិយាបន្ន និងចីរភាពតាមរយៈការផ្តល់អាទិភាពទៅលើ ការពង្រឹងរដ្ឋបាលសាធារណៈ, ការអភិវឌ្ឍធនធានមនុស្ស, ការកសាងហេដ្ឋារចនាសម្ព័ន្ធ ទាំងរូបវន្ត និងឌីជីថល, និងការពង្រឹងប្រព័ន្ធគាំពារសង្គម ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រព័ន្ធសុខាភិបាល និងវិស័យហិរញ្ញវត្ថុ,
- ជំរុញការអនុវត្តកម្មវិធីកំណែទម្រង់នានា និងគោលនយោបាយអាទិភាព និងបន្តតម្រង់ទិសការប្រើប្រាស់ធនធានថវិកាជាតិ ដើម្បីជំរុញក្បាលម៉ាស៊ីនកំណើន,



8

- បន្តពង្រឹងគុណភាព និងពង្រីកវិសាលភាពនៃសេវាសាធារណៈ,
- កំណត់គោលការណ៍ក្នុងការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី សម្រាប់ទាំងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍,
- បន្តកែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា ដោយពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមវិស័យអាទិភាព និងបន្តពង្រឹងការផ្សារភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ,
- បន្តពង្រឹងការអនុវត្តថវិកាកម្មវិធីនៅគ្រប់ក្រសួង-ស្ថាប័ន (រួមបញ្ចូលរដ្ឋបាលរាជធានី-ខេត្ត) និងពង្រឹងគុណភាពព័ត៌មានសមិទ្ធកម្ម ដើម្បីចាប់ផ្តើមអនុវត្តថវិកាសមិទ្ធកម្ម តាមរយៈការអនុវត្តកិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំ និងការរៀបចំយន្តការសម្រាប់ធ្វើការវាយតម្លៃ និងការផ្តល់ព័ត៌មានពីសមិទ្ធកម្ម,
- បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ដោយជំរុញការខ្ចីឱ្យអស់លទ្ធភាព ប៉ុន្តែសម្រាប់តែវិស័យអាទិភាព ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ជាពិសេសវិស័យបង្កើនផលិតភាពផលិតកម្ម ជំរុញការតភ្ជាប់ និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែង និង
- បន្តពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS ដល់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយចាប់ផ្តើមអនុវត្តស្វ័យប្រវត្តិកម្មចំណាយ និងដាក់អនុវត្តចំណាត់ថ្នាក់ថវិកាទាំង ៧ ។

## ៥. សេចក្តីសន្និដ្ឋាន

**៤៧.** ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២២ ត្រូវបានរៀបចំឡើងសំដៅបន្តរក្សាលំនឹងសេដ្ឋកិច្ចកម្ពុជា និងជីវភាពប្រជាជន ជាពិសេសការស្តារ និងជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ច ដើម្បីត្រឡប់ទៅរកគន្លងកំណើន ដោយផ្តោតលើការគ្រប់គ្រងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ និងការកែទម្រង់ជារចនាសម្ព័ន្ធ ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវភាពធន់សង្គម-សេដ្ឋកិច្ច ដែលនឹងធ្វើឱ្យកម្ពុជាខ្លាំងជាងមុនពេលមានវិបត្តិ ។ ជាក់ស្តែង ក្របខ័ណ្ឌនេះមានគោលដៅគាំទ្រការជំរុញកំណើនសេដ្ឋកិច្ចឆ្នាំ ២០២២ ឱ្យសម្រេចបានក្នុងរង្វង់ ៥,៧% ជាមួយនឹង អត្រាអតិផរណាដែលអាចគ្រប់គ្រងបានក្នុងរង្វង់ ៣,០% និងស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤ ០៦៥ រៀលក្នុងមួយដុល្លារអាមេរិក ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តតាមដានការវិវឌ្ឍនៃស្ថានភាពសង្គម និងសេដ្ឋកិច្ច ព្រមទាំងដាក់ឱ្យអនុវត្តនូវវិធានការអន្តរាគមន៍សមស្រប និងទាន់ពេលវេលា សំដៅដោះស្រាយផលប៉ះពាល់នានាពីវិបត្តិជំងឺកូវីដ-១៩ ដែលនៅបន្តអូសបន្លាយ ព្រមទាំងត្រៀមជំរុញសេដ្ឋកិច្ចឱ្យវិលត្រឡប់ទៅរកគន្លងកំណើន ។ ទន្ទឹមនេះ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ត្រូវប្រព្រឹត្តទៅដោយមានការប្រុងប្រយ័ត្នខ្ពស់ ដោយឈរលើស្មារតីបុរេសកម្ម និងការទទួលខុសត្រូវខ្ពស់, ដើម្បីអាចឆ្លើយតបបានទៅនឹងសភាពការណ៍ជាក់ស្តែងក្នុងគោលដៅធានាបាននូវស្ថិរភាពហិរញ្ញវត្ថុសាធារណៈ, ជាពិសេសបន្តពង្រឹងការកៀរគរចំណូលថវិការដ្ឋឱ្យអស់សក្តានុពល ព្រម-

ទាំងពង្រឹងប្រសិទ្ធភាពចំណាយទាំងក្នុងកម្រិតវិភាជន៍ និងប្រើប្រាស់ថវិកា សំដៅសម្រេចបាននូវឱនភាពថវិកាសរុបក្នុងអត្រា ៧,៧៦% នៃ ផសស ។

៤៨. ជារួម ដើម្បីធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការសម្រេចឱ្យបាននូវវិធានការ និងគោលដៅទាំងឡាញដែលបានដាក់ចេញ សំដៅបន្តប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ រួមជាមួយនឹងការបែងចែកវ៉ាក់សាំងឱ្យទាន់ពេលវេលា, ពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចជាតិ និងបង្កើនភាពប្រកួតប្រជែងកម្ពុជាឱ្យកាន់តែប្រសើរជាងមុន សំដៅជំរុញសកម្មភាពអាជីវកម្ម-វិនិយោគ ក្នុងគ្រប់វិស័យ ជាពិសេសការសម្របខ្លួនទៅនឹងប្រក្រតីភាពថ្មី (new normal) នៃដំណើរការអភិវឌ្ឍន៍ ។

❋❋❋✧❋❋❋

## ឧបសម្ព័ន្ធ ១÷ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច (២០១៨-២០២៤)

| សូចនាករ | 2018 | 2019 | 2020ប. | 2021ព្យ. | 2022ព្យ. | 2023ព្យ. | 2024ព្យ. |
|---|---|---|---|---|---|---|---|
| ផសស ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | **99,544** | **110,014** | **109,062** | **116,711** | **127,023** | **138,250** | **151,539** |
| ផសស សម្រាប់ម្នាក់ (ដុល្លារអាមេរិក) | 1,563 | 1,700 | 1,653 | 1,753 | 1,884 | 2,026 | 2,195 |
| កំណើន ផសស ពិត (%) | **7.5%** | **7.1%** | **-3.1%** | **4.0%** | **5.7%** | **6.3%** | **6.9%** |
| អត្រាបរិត្តិផរណា ផសស (កំណើនប្រចាំឆ្នាំ) | 3.1% | 3.2% | 2.3% | 2.9% | 3.0% | 2.4% | 2.5% |
| អត្រាអតិផរណា (កំណើនជាមធ្យមប្រចាំឆ្នាំ) | 2.5% | 1.8% | 2.9% | 3.1% | 3.0% | 3.0% | 3.0% |
| អត្រាប្តូរប្រាក់ (រៀល/ ដុល្លារអាមេរិក) | 4,045 | 4,055 | 4,080 | 4,065 | 4,065 | 4,065 | 4,065 |
| ការនាំចេញ (%នៃ ផសស) | 52.7% | 55.2% | 64.9% | 57.8% | 58.7% | 60.9% | 63.0% |
| ការនាំចូល (%នៃ ផសស) | 76.4% | 82.0% | 75.4% | 75.9% | 76.5% | 78.0% | 79.3% |
| សមតុល្យពាណិជ្ជកម្ម (%នៃ ផសស) | -23.7% | -26.7% | -10.6% | -18.1% | -17.8% | -17.1% | -16.2% |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) (%នៃ ផសស) | -12.2% | -15.5% | -6.6% | -14.7% | -12.8% | -12.2% | -10.0% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | 14,629 | 18,763 | 21,334 | 21,617 | 22,118 | 22,732 | 24,118 |
| ចំនួនខែនៃការនាំចូល | 8.0 | 8.8 | 11.6 | 10.9 | 10.1 | 9.3 | 9.0 |

ប្រភពៈ ធនាគារជាតិនៃកម្ពុជា (វិស័យខាងក្រៅឆ្នាំ ២០១៩ ត្រីមាសទី ៣) និងការព្យាករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបសម្ព័ន្ធ ២៖ ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ

## ក. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ: ២០២០-២០២២

*ផសស តាមថ្លៃចរន្តឆ្នាំ ២០២០ (ជាក់ស្ដែង)* 109,062
*ផសស តាមថ្លៃចរន្តឆ្នាំ ២០២១ (គម្រោង)* 116,711
*ផសស តាមថ្លៃចរន្តឆ្នាំ ២០២២ (គម្រោង)* 127,023

*ឯកតា៖ ប៊ីលានរៀល*

| ចំណូល-ចំណាយ | ២០២០ | | | | | ២០២១ | | | | ២០២២ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ | បណ្ដោះអាសន្ន (*) | បណ្ដោះ. (%ច្បាប់) | បណ្ដោះ. (%២០១៩) | បណ្ដោះ. (%ផសស) | ច្បាប់ | កែតម្រូវ | កែតម្រូវ (%ច្បាប់) | កែតម្រូវ (%ផសស) | គ្រោង | % ២០២១ កែតម្រូវ | % ២០២១ ច្បាប់ | គ្រោង (%ផសស) |
| **ចំណូលក្នុងប្រទេសសរុប** | **26,336** | **23,462** | **89.1%** | **84.4%** | **21.51%** | **21,446** | **24,421** | **113.9%** | **20.92%** | **27,268** | **111.7%** | **127.1%** | **21.47%** |
| ចំណូលចរន្ត | 26,143 | 23,277 | 89.0% | 84.3% | 21.34% | 21,224 | 24,200 | 114.0% | 20.73% | 27,025 | 111.7% | 127.3% | 21.28% |
| ចំណូលមូលធន | 193 | 185 | 95.8% | 102.1% | 0.17% | 221 | 221 | 100.0% | 0.19% | 243 | 109.8% | 109.8% | 0.19% |
| **រដ្ឋបាលកណ្ដាល** | | | | | | | | | | | | | |
| **ចំណូលចរន្ត** | **23,899** | **21,193** | **88.7%** | **83.5%** | **19.43%** | **19,706** | **21,726** | **110.3%** | **18.62%** | **24,451** | **112.5%** | **124.1%** | **19.25%** |
| ចំណូលសារពើពន្ធ | 21,091 | 19,258 | 91.3% | 87.3% | 17.66% | 17,520 | 19,723 | 112.6% | 16.90% | 22,082 | 112.0% | 126.0% | 17.38% |
| ចំណូលមិនមែនសារពើពន្ធ | 2,808 | 1,935 | 68.9% | 57.9% | 1.77% | 2,186 | 2,003 | 91.6% | 1.72% | 2,369 | 118.3% | 108.4% | 1.87% |
| **ចំណូលមូលធន** | **193** | **185** | **95.8%** | **102.1%** | **0.17%** | **221** | **221** | **100.0%** | **0.19%** | **243** | **109.8%** | **109.8%** | **0.19%** |
| **រាជធានី-ខេត្ត** | | | | | | | | | | | | | |
| **ចំណូលចរន្ត** | **2,244** | **2,084** | **92.9%** | **94.1%** | **1.91%** | **1,518** | **2,474** | **162.9%** | **2.12%** | **2,574** | **104.0%** | **169.5%** | **2.03%** |
| ចំណូលសារពើពន្ធ | 2,086 | 1,928 | 92.4% | 91.2% | 1.77% | 1,050 | 2,011 | 191.5% | 1.72% | 2,193 | 109.0% | 208.8% | 1.73% |
| ចំណូលមិនមែនសារពើពន្ធ | 157 | 156 | 98.9% | 155.1% | 0.14% | 468 | 463 | 98.9% | 0.40% | 381 | 82.3% | 81.4% | 0.30% |
| **ចំណូលតាមអង្គភាព** | | | | | | | | | | | | | |
| អគ្គនាយកដ្ឋានពន្ធដារ | 11,531 | 11,514 | 99.8% | 102.2% | 10.56% | 9,074 | 11,384 | 125.5% | 9.75% | 12,804 | 112.5% | 141.1% | 10.08% |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 11,646 | 9,672 | 83.1% | 75.0% | 8.87% | 9,496 | 10,350 | 109.0% | 8.87% | 11,470 | 110.8% | 120.8% | 9.03% |
| អគ្គនាយកដ្ឋានចំណូលផ្សេងៗ | 2,966 | 2,091 | 70.5% | 60.7% | 1.92% | 2,654 | 2,466 | 92.9% | 2.11% | 2,750 | 111.5% | 103.6% | 2.17% |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ចំណាយសរុប** | **33,340** | **32,279** | **96.8%** | **112.6%** | **29.60%** | **32,010** | **32,010** | **100.0%** | **27.43%** | **37,125** | **116.0%** | **116.0%** | **29.23%** |
| ចំណាយចរន្ត | 19,818 | 19,486 | 98.3% | 103.8% | 17.87% | 18,751 | 18,751 | 100.0% | 16.07% | 21,356 | 113.9% | 113.9% | 16.81% |
| ចំណាយមូលធន | 13,521 | 12,793 | 94.6% | 129.1% | 11.73% | 13,259 | 13,259 | 100.0% | 11.36% | 15,769 | 118.9% | 118.9% | 12.41% |
| **រដ្ឋបាលកណ្ដាល** | | | | | | | | | | | | | |
| **ចំណាយចរន្ត** | **18,037** | **17,686** | **98.1%** | **98.9%** | **16.22%** | **17,447** | **17,447** | **100.0%** | **14.95%** | **19,297** | **110.6%** | **110.6%** | **15.19%** |
| **ចំណាយមូលធន** | **11,953** | **11,427** | **95.6%** | **133.8%** | **10.48%** | **11,859** | **11,859** | **100.0%** | **10.16%** | **13,777** | **116.2%** | **116.2%** | **10.85%** |
| - ដោយហិរញ្ញប្បទានក្នុងប្រទេស | 5,900 | 5,677 | 96.2% | 161.5% | 5.20% | 6,394 | 6,394 | 100.0% | 5.48% | 7,963 | 124.5% | 124.5% | 6.27% |
| - ដោយហិរញ្ញប្បទានក្រៅប្រទេស | 6,053 | 5,751 | 95.0% | 114.4% | 5.27% | 5,466 | 5,466 | 100.0% | 4.68% | 5,813 | 106.4% | 106.4% | 4.58% |
| **រាជធានីខេត្ត** | | | | | | | | | | | | | |
| ចំណាយចរន្ត | 2,867 | 3,298 | 115.0% | 124.3% | 3.02% | 2,365 | 2,365 | 100.0% | 2.03% | 3,182 | 134.6% | 134.6% | 2.51% |
| ចំណាយមូលធន | 462 | 283 | 61.3% | 59.1% | 0.26% | 214 | 214 | 100.0% | 0.18% | 515 | 240.3% | 240.3% | 0.41% |
| **ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ** | 1,085 | 1,498 | 138.0% | 84.5% | 1.37% | 1,060 | 1,060 | 100.0% | 0.91% | 1,123 | 105.9% | 105.9% | 0.88% |
| **តុល្យភាព** | | | | | | | | | | | | | |
| អតិរេកថវិកាចរន្ត | 6,325 | 3,791 | 59.9% | 42.9% | 3.48% | 2,473 | 5,449 | 220.3% | 4.67% | 5,669 | 104.0% | 229.2% | 4.46% |
| ឱនភាពសរុប | (7,003) | (10,093) | 144.1% | 1138.8% | -9.25% | (10,564) | (7,589) | 71.8% | -6.50% | (9,857) | 129.9% | 93.3% | -7.76% |
| **ហិរញ្ញប្បទាន នៃឱនភាព** | **7,003** | **10,093** | **144.1%** | **1138.8%** | **9.25%** | **10,564** | **7,589** | **71.8%** | **6.50%** | **9,857** | **129.9%** | **93.3%** | **7.76%** |
| ក្នុងប្រទេស | (406) | 1,553 | -382.7% | -28.4% | 1.42% | 3,056 | 80 | 2.6% | 0.07% | 1,303 | 1625.8% | 42.7% | 1.03% |
| ក្រៅប្រទេស | 7,409 | 8,539 | 115.3% | 134.3% | 7.83% | 7,508 | 7,508 | 100.0% | 6.43% | 8,554 | 113.9% | 113.9% | 6.73% |
| ទ្រទ្រង់ថវិកាដោយដៃគូអភិវឌ្ឍន៍ | 250 | 1,706 | 682.6% | 380.4% | 1.56% | 858 | 858 | 100.0% | 0.73% | 1,263 | 147.2% | 147.2% | 0.99% |
| មូលធនក្រៅប្រទេស | 6,053 | 5,751 | 95.0% | 114.4% | 5.27% | 5,466 | 5,466 | 100.0% | 4.68% | 5,813 | 106.4% | 106.4% | 4.58% |
| ការទូទាត់ប្រាក់កម្ចី | 1,106 | 1,082 | 97.9% | 122.4% | 0.99% | 1,185 | 1,185 | 100.0% | 1.02% | 1,478 | 124.7% | 124.7% | 1.16% |

*(*) សម្គាល់ ៖ តួលេខបណ្ដោះអាសន្នគិតត្រឹមថ្ងៃ ១១ ខែកុម្ភៈ ឆ្នាំ ២០២១*

## ខ. ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ២០២១-២០២៤

| ចំណូល/ចំណាយ (ប៊ីលានរៀល) | 2020 បណ្តោះ | 2021 ច្បាប់ | 2021 កែ. | 2022 ព្យ. | 2023 ព្យ. | 2024 ព្យ. |
|---|---|---|---|---|---|---|
| ចំណាយបន្ទុកបុគ្គលិកជា %នៃចំណាយចរន្តសរុប | 46.4% | 49.7% | 49.7% | 48.4% | 46.9% | 47.3% |
| **I. ចំណូលក្នុងស្រុក** | **23,462** | **21,446** | **24,421** | **27,268** | **30,503** | **34,259** |
| **I.1 ចំណូលចរន្តសរុប** | **23,277** | **21,224** | **24,200** | **27,025** | **30,217** | **33,945** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 9,672 | 9,496 | 10,350 | 11,470 | 12,863 | 14,378 |
| អគ្គនាយកដ្ឋានពន្ធដារ | 11,514 | 9,074 | 11,384 | 12,804 | 14,290 | 16,157 |
| ចំណូលមិនមែនសារពើពន្ធសរុប | 2,091 | 2,654 | 2,466 | 2,750 | 3,065 | 3,409 |
| **I.2 ចំណូលមូលធន** | **185** | **221** | **221** | **243** | **286** | **314** |
| **II. ចំណាយសរុប** | **32,279** | **32,010** | **32,010** | **37,125** | **40,363** | **43,110** |
| **II.1 ចំណាយចរន្តសរុប** | **19,486** | **18,751** | **18,751** | **21,356** | **24,440** | **26,886** |
| បន្ទុកបុគ្គលិក | 9,037 | 9,327 | 9,327 | 10,344 | 11,472 | 12,723 |
| បន្ទុកមិនមែនបុគ្គលិក | 10,450 | 9,424 | 9,424 | 11,012 | 12,968 | 14,163 |
| **II.2 ចំណាយមូលធនសរុប** | **12,793** | **13,259** | **13,259** | **15,769** | **15,923** | **16,223** |
| ហិរញ្ញប្បទានក្នុងប្រទេសសរុប | 5,960 | 6,608 | 6,608 | 8,478 | 7,627 | 6,613 |
| ទូទាត់ការខ្ចី | 1,082 | 1,185 | 1,185 | 1,478 | 1,620 | 1,776 |
| ហិរញ្ញប្បទានក្រៅប្រទេស | 5,751 | 5,466 | 5,466 | 5,813 | 6,677 | 7,835 |
| **III. អតិរេកចរន្ត** | **3,791** | **2,473** | **5,449** | **5,669** | **5,777** | **7,059** |
| **IV. និនភាព/អតិរេកសរុប** | **(10,093)** | **(10,564)** | **(7,589)** | **(9,857)** | **(9,861)** | **(8,851)** |
| **V. ដកសន្សំ** | **(2,636)** | **(4,241)** | **(1,265)** | **(2,781)** | **(2,327)** | **(766)** |
| **កំណើនប្រចាំឆ្នាំ** | 2020ប./ 2020ច្ប. | 2021ច្ប./ 2020ប. | 2021កែ./ 2020ប. | 2022ព្យ./ 2021កែ | 2023ព្យ. | 2024ព្យ. |
| **I. ចំណូលក្នុងស្រុក** | **-10.9%** | **-8.6%** | **4.1%** | **11.7%** | **11.9%** | **12.3%** |
| **I.1 ចំណូលចរន្តសរុប** | **-11.0%** | **-8.8%** | **4.0%** | **11.7%** | **11.8%** | **12.3%** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | -16.9% | -1.8% | 7.0% | 10.8% | 12.1% | 11.8% |
| អគ្គនាយកដ្ឋានពន្ធដារ | -0.2% | -21.2% | -1.1% | 12.5% | 11.6% | 13.1% |
| ចំណូលមិនមែនសារពើពន្ធសរុប | -29.5% | 26.9% | 17.9% | 11.5% | 11.4% | 11.3% |
| **I.2 ចំណូលមូលធន** | -4.2% | 19.4% | 19.4% | 9.8% | 17.6% | 10.1% |
| **II. ចំណាយសរុប** | **-3.2%** | **-0.8%** | **-0.8%** | **16.0%** | **8.7%** | **6.8%** |
| **II.1 ចំណាយចរន្តសរុប** | **-1.7%** | **-3.8%** | **-3.8%** | **13.9%** | **14.4%** | **10.0%** |
| បន្ទុកបុគ្គលិក | -1.1% | 3.2% | 3.2% | 10.9% | 10.9% | 10.9% |
| បន្ទុកមិនមែនបុគ្គលិក | -2.2% | -9.8% | -9.8% | 16.8% | 17.8% | 9.2% |
| **II.2 ចំណាយមូលធនសរុប** | **-5.4%** | **3.6%** | **3.6%** | **18.9%** | **1.0%** | **1.9%** |
| ហិរញ្ញប្បទានក្នុងប្រទេសសរុប | *-6.3%* | *10.9%* | *10.9%* | *28.3%* | *-10.0%* | *-13.3%* |
| ទូទាត់ការខ្ចី | -2.1% | 9.5% | 9.5% | 24.7% | 9.6% | 9.6% |
| ហិរញ្ញប្បទានក្រៅប្រទេស | -5.0% | -5.0% | -5.0% | 6.4% | 14.8% | 17.3% |

| ផលធៀបនៃផ.ស.ស | 2020 បណ្ដោះ | 2021 ច្បាប់ | 2021 កែ. | 2022 ព្យ. | 2023 ព្យ. | 2024 ព្យ. |
|---|---|---|---|---|---|---|
| I. ចំណូលក្នុងស្រុក | 21.51% | 18.37% | 20.92% | 21.47% | 22.06% | 22.61% |
| **I.1 ចំណូលចរន្តសរុប** | **21.34%** | **18.19%** | **20.73%** | **21.28%** | **21.86%** | **22.40%** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 8.87% | 8.14% | 8.87% | 9.03% | 9.30% | 9.49% |
| អគ្គនាយកដ្ឋានពន្ធដារ | 10.56% | 7.78% | 9.75% | 10.08% | 10.34% | 10.66% |
| ចំណូលមិនមែនសារពើពន្ធសរុប | 1.92% | 2.27% | 2.11% | 2.17% | 2.22% | 2.25% |
| **I.2 ចំណូលមូលធន** | **0.17%** | **0.19%** | **0.19%** | **0.19%** | **0.21%** | **0.21%** |
| II. ចំណាយសរុប | 29.60% | 27.43% | 27.43% | 29.23% | 29.20% | 28.45% |
| **II.1 ចំណាយចរន្តសរុប** | **17.87%** | **16.07%** | **16.07%** | **16.81%** | **17.68%** | **17.74%** |
| បន្ទុកបុគ្គលិក | 8.29% | 7.99% | 7.99% | 8.14% | 8.30% | 8.40% |
| បន្ទុកមិនមែនបុគ្គលិក | 9.58% | 8.08% | 8.08% | 8.67% | 9.38% | 9.35% |
| **II.2 ចំណាយមូលធនសរុប** | **11.73%** | **11.36%** | **11.36%** | **12.41%** | **11.52%** | **10.71%** |
| ហិរញ្ញប្បទាន ក្នុងប្រទេសសរុប | *5.46%* | *5.66%* | *5.66%* | *6.67%* | *5.52%* | *4.36%* |
| ទូទាត់ការខ្ចី | 0.99% | 1.02% | 1.02% | 1.16% | 1.17% | 1.17% |
| ហិរញ្ញប្បទាន ក្រៅប្រទេស | 5.27% | 4.68% | 4.68% | 4.58% | 4.83% | 5.17% |
| III. អតិរេកចរន្ត | 3.48% | 2.12% | 4.67% | 4.46% | 4.18% | 4.66% |
| IV. ឱនភាព/អតិរេកសរុប | -9.25% | -9.05% | -6.50% | -7.76% | -7.13% | -5.84% |
| V. ដកសន្សំ | -2.42% | -3.63% | -1.08% | -2.19% | -1.68% | -0.51% |

## ខ.១ ចំណាយតាមវិស័យរយៈពេលមធ្យម ២០២១-២០២៤

| ចំណាយតាមវិស័យ (ប៊ីលានរៀល) | 2021 ច្បាប់ | 2021 កែ. | 2022 គ្រ. | 2023 គ្រ. | 2024 គ្រ. |
|---|---|---|---|---|---|
| **1. ចំណាយសរុបតាមវិស័យ (រួមបញ្ចូលហិរញ្ញប្បទានក្រៅប្រទេស)** | **32,010** | **32,010** | **37,125** | **40,363** | **43,110** |
| **1.1 ថ្នាក់ជាតិ** | **30,491** | **30,491** | **34,551** | **37,553** | **39,971** |
| ក.វិស័យរដ្ឋបាលទូទៅ | 2,112 | 2,508 | 2,271 | 2,387 | 2,520 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *157* | *157* | *198* | *198* | *198* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 4,870 | 4,870 | 5,305 | 5,834 | 6,419 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *120* | *120* | *110* | *110* | *110* |
| គ.វិស័យសង្គមកិច្ច | 9,720 | 9,806 | 8,939 | 9,190 | 10,067 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *1,986* | *1,986* | *1,038* | *546* | *546* |
| ឃ.វិស័យសេដ្ឋកិច្ច | 8,493 | 8,539 | 10,915 | 12,083 | 12,734 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *2,603* | *2,603* | *4,101* | *4,360* | *3,825* |
| ង.ចំណាយផ្សេងៗ | 5,296 | 4,768 | 7,122 | 8,058 | 8,232 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *1,528* | *1,528* | *2,516* | *1,851* | *1,307* |
| **1.2 ថ្នាក់ក្រោមជាតិ** | **2,579** | **2,579** | **3,697** | **4,253** | **4,755** |
| **2. ចំណាយសរុបតាមវិស័យ (មិនរួមបញ្ចូលហិរញ្ញប្បទានក្រៅប្រទេស)** | **26,544** | **26,544** | **31,311** | **33,687** | **35,275** |
| **1.1 ថ្នាក់ជាតិ** | **25,026** | **25,026** | **28,738** | **30,876** | **32,137** |
| ក.វិស័យរដ្ឋបាលទូទៅ | 1,972 | 2,368 | 2,096 | 2,187 | 2,285 |
| *ក្នុងនោះ ចំណាយចរន្ត* | *1,816* | *2,212* | *1,899* | *1,989* | *2,087* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 4,836 | 4,837 | 5,305 | 5,834 | 6,419 |
| *ក្នុងនោះ ចំណាយចរន្ត* | *4,716* | *4,717* | *5,195* | *5,724* | *6,309* |
| គ.វិស័យសង្គមកិច្ច | 8,858 | 8,944 | 8,532 | 8,723 | 9,518 |
| *ក្នុងនោះ ចំណាយចរន្ត* | *6,873* | *6,958* | *7,494* | *8,177* | *8,972* |
| ឃ.វិស័យសេដ្ឋកិច្ច | 4,063 | 4,109 | 5,683 | 6,074 | 5,683 |
| *ក្នុងនោះ ចំណាយចរន្ត* | *1,460* | *1,506* | *1,582* | *1,714* | *1,858* |
| ង.ចំណាយផ្សេងៗ | 5,296 | 4,768 | 7,122 | 8,058 | 8,232 |
| *ក្នុងនោះ ចំណាយចរន្ត* | *2,583* | *2,054* | *3,127* | *4,587* | *5,149* |
| ឧបត្ថម្ភធនជូនថ្នាក់ក្រោមជាតិ | 1,060 | 1,060 | 1,123 | 1,443 | 1,617 |
| **1.2 ថ្នាក់ក្រោមជាតិ** | **2,579** | **2,579** | **3,697** | **4,253** | **4,755** |

| កំណើនប្រចាំឆ្នាំ | 2021 ច្បា/ 2020 ប. | 2021 កែ/ 2020 ប. | 2022 គ្រ./ 2021 កែ. | 2023 គ្រ. | 2024 គ្រ. |
|---|---|---|---|---|---|
| **1. ចំណាយសរុបតាមវិស័យ (រួមបញ្ចូលហិរញ្ញប្បទានក្រៅប្រទេស)** | **-0.8%** | **-0.8%** | **16.0%** | **8.7%** | **6.8%** |
| **1.1 ថ្នាក់ជាតិ** | **1.0%** | **1.0%** | **13.3%** | **8.7%** | **6.4%** |
| ក.វិស័យរដ្ឋបាលទូទៅ | -33.0% | -20.4% | -9.5% | 5.1% | 5.6% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *528.7%* | *528.7%* | *26.2%* | *0.0%* | *0.0%* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | -3.5% | -3.5% | 8.9% | 10.0% | 10.0% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *-7.5%* | *-7.5%* | *-8.3%* | *0.0%* | *0.0%* |
| គ.វិស័យសង្គមកិច្ច | 15.2% | 16.2% | -8.8% | 2.8% | 9.5% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *611.4%* | *611.4%* | *-47.7%* | *-47.4%* | *0.0%* |
| ឃ.វិស័យសេដ្ឋកិច្ច | 14.1% | 14.7% | 27.8% | 10.7% | 5.4% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *103.8%* | *103.8%* | *57.5%* | *6.3%* | *-12.3%* |
| ង.ចំណាយផ្សេងៗ | -13.4% | -22.0% | 49.4% | 13.2% | 2.2% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *-61.5%* | *-61.5%* | *64.6%* | *-26.4%* | *-29.4%* |
| **1.2 ថ្នាក់ក្រោមជាតិ** | **-28.0%** | **-28.0%** | **43.4%** | **15.1%** | **11.8%** |
| **2. ចំណាយសរុបតាមវិស័យ (មិនរួមបញ្ចូលហិរញ្ញប្បទានក្រៅប្រទេស)** | **0.1%** | **0.1%** | **18.0%** | **7.6%** | **4.7%** |
| **1.1 ថ្នាក់ជាតិ** | **2.4%** | **2.4%** | **14.8%** | **7.4%** | **4.1%** |
| ក.វិស័យរដ្ឋបាលទូទៅ | -36.1% | -23.3% | -11.5% | 4.3% | 4.5% |
| *ក្នុងនោះ ចំណាយចរន្ត* | *-36.2%* | *-22.3%* | *-14.1%* | *4.8%* | *4.9%* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | -6.2% | -6.1% | 9.7% | 10.0% | 10.0% |
| *ក្នុងនោះ ចំណាយចរន្ត* | *0.5%* | *0.6%* | *10.1%* | *10.2%* | *10.2%* |
| គ.វិស័យសង្គមកិច្ច | 15.6% | 16.7% | -4.6% | 2.2% | 9.1% |
| *ក្នុងនោះ ចំណាយចរន្ត* | *-0.6%* | *0.6%* | *7.7%* | *9.1%* | *9.7%* |
| ឃ.វិស័យសេដ្ឋកិច្ច | 58.5% | 60.3% | 38.3% | 6.9% | -6.4% |
| *ក្នុងនោះ ចំណាយចរន្ត* | *-3.4%* | *-0.3%* | *5.0%* | *8.4%* | *8.4%* |
| ង.ចំណាយផ្សេងៗ | -11.4% | -20.3% | 49.4% | 13.2% | 2.2% |
| *ក្នុងនោះ ចំណាយចរន្ត* | *49.8%* | *19.2%* | *52.2%* | *46.7%* | *12.3%* |
| ឧបត្ថម្ភធនជូនថ្នាក់ក្រោមជាតិ | -29.2% | -29.2% | 5.9% | 28.4% | 12.1% |
| **1.2 ថ្នាក់ក្រោមជាតិ** | **-28.0%** | **-28.0%** | **43.4%** | **15.1%** | **11.8%** |

| ផលធៀបនៃផ.ស.ស | 2021 ច្បាប់ | 2021 កែ. | 2022 ព្យ. | 2023 ព្យ. | 2024 ព្យ. |
|---|---|---|---|---|---|
| **1. ចំណាយសរុបតាមវិស័យ (រួមបញ្ចូលហិរញ្ញប្បទានក្រៅប្រទេស)** | **27.43%** | **27.43%** | **29.23%** | **29.20%** | **28.45%** |
| **1.1 ថ្នាក់ជាតិ** | **26.13%** | **26.13%** | **27.20%** | **27.16%** | **26.38%** |
| ក.វិស័យរដ្ឋបាលទូទៅ | 1.81% | 2.15% | 1.79% | 1.73% | 1.66% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.13%* | *0.13%* | *0.16%* | *0.14%* | *0.13%* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 4.17% | 4.17% | 4.18% | 4.22% | 4.24% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.10%* | *0.10%* | *0.09%* | *0.08%* | *0.07%* |
| គ.វិស័យសង្គមកិច្ច | 8.33% | 8.40% | 7.04% | 6.65% | 6.64% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *1.70%* | *1.70%* | *0.82%* | *0.39%* | *0.36%* |
| ឃ.វិស័យសេដ្ឋកិច្ច | 7.28% | 7.32% | 8.59% | 8.74% | 8.40% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *2.23%* | *2.23%* | *3.23%* | *3.15%* | *2.52%* |
| ង.ចំណាយផ្សេងៗ | 4.54% | 4.09% | 5.61% | 5.83% | 5.43% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *1.31%* | *1.31%* | *1.98%* | *1.34%* | *0.86%* |
| **1.2 ថ្នាក់ក្រោមជាតិ** | **2.21%** | **2.21%** | **2.91%** | **3.08%** | **3.14%** |
| **2. ចំណាយសរុបតាមវិស័យ (មិនរួមបញ្ចូលហិរញ្ញប្បទានក្រៅប្រទេស)** | **22.74%** | **22.74%** | **24.65%** | **24.37%** | **23.28%** |
| **1.1 ថ្នាក់ជាតិ** | **21.44%** | **21.44%** | **22.62%** | **22.33%** | **21.21%** |
| ក.វិស័យរដ្ឋបាលទូទៅ | **1.69%** | **2.03%** | **1.65%** | **1.58%** | **1.51%** |
| *ក្នុងនោះ ចំណាយចរន្ត* | *1.56%* | *1.89%* | *1.49%* | *1.44%* | *1.38%* |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | **4.14%** | **4.14%** | **4.18%** | **4.22%** | **4.24%** |
| *ក្នុងនោះ ចំណាយចរន្ត* | *4.04%* | *4.04%* | *4.09%* | *4.14%* | *4.16%* |
| គ.វិស័យសង្គមកិច្ច | **7.59%** | **7.66%** | **6.72%** | **6.31%** | **6.28%** |
| *ក្នុងនោះ ចំណាយចរន្ត* | *5.89%* | *5.96%* | *5.90%* | *5.91%* | *5.92%* |
| ឃ.វិស័យសេដ្ឋកិច្ច | **3.48%** | **3.52%** | **4.47%** | **4.39%** | **3.75%** |
| *ក្នុងនោះ ចំណាយចរន្ត* | *1.25%* | *1.29%* | *1.25%* | *1.24%* | *1.23%* |
| ង.ចំណាយផ្សេងៗ | **4.54%** | **4.09%** | **5.61%** | **5.83%** | **5.43%** |
| *ក្នុងនោះ ចំណាយចរន្ត* | *2.21%* | *1.76%* | *2.46%* | *3.32%* | *3.40%* |
| ឧបត្ថម្ភធនជូនថ្នាក់ក្រោមជាតិ | 0.91% | 0.91% | 0.88% | 1.04% | 1.07% |
| **1.2 ថ្នាក់ក្រោមជាតិ** | **2.21%** | **2.21%** | **2.91%** | **3.08%** | **3.14%** |